# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center

*“ គេមិនដែលយកឈើពុក ឈើស្អុយរលួយទៅឆ្លាក់ធ្វើព្រះ ហើយយកព្រះនោះ មកទេសនាឲ្យប្រជាជនស្តាប់នោះទេ” ។*

***- ជនជាប់ចោទ នួន ជា និយាយសំដៅដល់ ឌុច***

## ផ្នែកទី១ ៖ ទិដ្ឋភាពទូទៅ

នៅសប្តាហ៍នេះ គឺជាការចាប់ផ្តើមផ្តល់សក្ខីកម្ម អំពីរចនាសម្ព័ន្ធរដ្ឋបាល (ថ្នាក់មជ្ឈិម និងថ្នាក់ជាតិ) ប្រព័ន្ធទំនាក់ទំនងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងតួនាទីរបស់ជនជាប់ចោទ។

**នួន ជា** ក៏បានផ្តល់សក្ខីកម្មនៅសវនាការផ្នែកទី២។ អង្គជំនុំជម្រះ បានអនុញ្ញាតតាមសំណូមពររបស់ **នួន ជា** ក្នុងការធ្វើសេចក្តីថ្លែងការណ៍បឋម មុនចាប់ផ្តើមដំណើរការសួរដេញដោល។ ប្រធានអង្គជំនុំជម្រះ **និល ណុន** បានបង្អាក់ជនជាប់ចោទមិនឲ្យធ្វើសេចក្តីថ្លែងដែលពាក់ព័ន្ធនឹងសវនាការផ្នែកទី១ ប៉ុន្តែទោះបីជាយ៉ាងណា មេធាវីអន្តរជាតិ **ម៉ៃឃើល ផេស្តមិន** បានបញ្ចុះបញ្ចូលអង្គជំនុំជម្រះអនុញ្ញាតឲ្យកូនក្តីខ្លួនបន្តសេចក្តីថ្លែងការណ៍របស់ខ្លួន។ **នួន ជា** បានបញ្ចប់សេចក្តីថ្លែងការណ៍ ដោយស្នើឲ្យអង្គជំនុំជម្រះបន្តកិច្ចសវនាការទៅលើប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ បើមិនដូច្នេះទេ គាត់នឹងប្រើប្រាស់សិទ្ធិនៅស្ងៀមមិននិយាយស្តី។ អង្គជំនុំជម្រះមិនបានបដិសេធលើសំណើនេះទេ ប៉ុន្តែនឹងចោទសួរដេញដោល **នួន ជា** អំពីបញ្ហានៅក្នុងសវនាការផ្នែកទី២នេះ ដូចនេះនាំឲ្យ **នួន ជា** ប្រើប្រាស់សិទ្ធិនៅស្ងៀម។ ដោយសារមិនបានត្រៀមរៀបចំសាក្សីបម្រុងដូចនេះ អង្គជំនុំជម្រះបានផ្អាកដំណើរការសវនាការនៅព្រឹកនោះ និងកោះអញ្ជើញសាក្សី **កាំង ហ្គេចអ៊ាវ** ហៅ **“ ឌុច”** ដែលជាអតីតប្រធានមន្ទីរសន្តិសុខ ស-២១ មកផ្តល់សក្ខីកម្មនៅថ្ងៃរសៀល។ ការនេះធ្វើឲ្យសវនាការប្រព្រឹត្តទៅលឿនជាងកាលវិភាគកន្លះថ្ងៃ។

ព្រះរាជអាជ្ញាជាតិ **សេង ប៊ុនឃាង** និងព្រះរាជអាជ្ញាអន្តរជាតិ **វីល្លៀម ស្មីត** បានចោទសួរ **ឌុច** អំពីប្រវត្តិរបស់ **នួន ជា** ក្នុងការចូលជាសមាជិកបក្សកម្មុយនីស្តកម្ពុជា អំពីមុខងារ និងតួនាទីនៅក្នុងជួរបក្ស ព្រមទាំងអំពីទំនាក់ទំនងជាមួយបក្សក្រោយឆ្នាំ១៩៧៩។ **ឌុច** ក៏បានផ្តល់សក្ខីកម្ម អំពីមនោគមវិជ្ជា និងគោលនយោបាយបក្សផងដែរ។ ក្រុមមេធាវីការពារក្តី បានធ្វើការតតាំងនឹងសក្ខីកម្មរបស់សាក្សីជាបន្តបន្ទាប់ ដោយលើកហេតុផលថា សហព្រះរាជអាជ្ញាកំពុងចាត់ទុកសាក្សីថាជា *សាក្សីជំនាញ* និងសួរសំណួរក្រៅពីទំហំសវនាការផ្នែកទី១ នៃសំណុំរឿង០០២។

## ផ្នែកទី២ ៖ សេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ និងសក្ខីកម្មរបស់សាក្សី

យោងតាមសេចក្តីប្រកាសរបស់អង្គជំនុំជម្រះកាលពីសប្តាហ៍មុន អង្គជំនុំជម្រះនឹងផ្តល់ឱកាសឲ្យ **នួន ជា** ផ្តល់សក្ខីកម្មនៅព្រឹកថ្ងៃច័ន្ទ និងថ្ងៃពុធ ចំណែកឯ **ឌុច** វិញ នឹងមកផ្តល់សក្ខីកម្មនៅថ្ងៃអង្គារ និងព្រហស្បតិ៍។ ផ្ទុយទៅវិញ **នួន ជា** មិនបានផ្តល់សក្ខីកម្មទេ ហើយថែមទាំងប្រើប្រាស់សិទ្ធិនៅស្ងៀម។ កត្តានេះបានធ្វើឲ្យអង្គជំនុំជម្រះកោះអញ្ជើញ **ឌុច** មកផ្តល់សក្ខីកម្មមុនកាលកំណត់។ នៅក្នុងផ្នែកនេះ នឹងផ្តល់ព័ត៌មានសង្ខេបអំពីសេចក្តីថ្លែងការណ៍របស់ **នួន ជា** និងសក្ខីកម្មរបស់ **ឌុច** នៅក្នុងសប្តាហ៍នេះ។

### ក. សេចក្តីថ្លែងការណ៍របស់ នួន ជា

នៅព្រឹកថ្ងៃទី១៩ ខែមីនា **នួន ជា** បានអានសេចក្តីថ្លែងការណ៍ដែលធានាថា វាពាក់ព័ន្ធនឹងសវនាការផ្នែកទី២។ ទោះបីជាយ៉ាងណា ជំនួសឲ្យការផ្តល់ព័ត៌មានដែលមិនពាក់ព័ន្ធនឹងសវនាការផ្នែកទី២ គាត់បានបង្ហាញពីការខកបំណងចំពោះដំណើរការជំនុំជម្រះ និងបានលើកឡើងថា គាត់ និងមេធាវីខ្លួនបានលើកយកបញ្ហានេះដាក់មុខអង្គជំនុំជម្រះហើយ។ **នួន ជា** បានបន្តថា អង្គជំនុំជម្រះមិនបានខិតខំបើកកកាយពីរូបភាពប្រវត្តិសាស្ត្រកម្ពុជា ក្រោមការគ្រប់គ្រងរបស់បក្សកម្មុយនីស្តកម្ពុជាទេ និងបានលើកការកត់សម្គាល់ថា អង្គជំនុំជម្រះកាត់សេចក្តីតែខ្លួន ប៉ុន្តែមិនមែន *"ក្បាល និង កន្ទុយ"* នៃរបបកម្ពុជាប្រជាធិបតេយ្យ។ ឫសគល់នៃបញ្ហា និងផលវិបាកនៃព្រឹត្តិការណ៍មុនឆ្នាំ១៩៧៥ គួរយកមកពិចារណា ប្រសិនបើអង្គជំនុំជម្រះ និងប្រជាជនពិតជាចង់ស្វែងយល់អំពីមជ្ឈដ្ឋានប្រវត្តិសាស្ត្រនាខ្មែរសម័យនោះ ដូចជា (១) ការទម្លាក់គ្រាប់បែកមកលើប្រទេសកម្ពុជាចាប់ពីឆ្នាំ១៩៦៥ ដល់ ១៩៧៣ ដែលមិនត្រឹមតែបង្កឲ្យមនុស្សស្លាប់រាប់ពាន់នាក់ប៉ុណ្ណោះទេ ថែមទាំងបានបំផ្លាញហេដ្ឋារចនាសម្ព័ន្ធ និងផលិតផលកសិកម្មជាច្រើន (២) ការរីករាលដាលនៃជម្ងឺស្រេកឃ្លាន ភាពក្រីក្រ រោគរាតត្បាត ការស្លាប់ ការបំផ្លិចបំផ្លាញ អំពើពុករលួយ ភាពចលាចល និងអំពើហិង្សាបានធ្វើឲ្យស្ថានការណ៍កាន់តែអាក្រក់ទៅៗ (៣) ការចុះថយការផ្គត់ផ្គង់អាហារ (៤) កង្វះខាតសេវាកម្មវេជ្ជសាស្ត្រ និងជំនួយមនុស្សធម៌ និង (៥) ស្ថានការណ៍តានតឹងរវាងប្រទេសវៀតណាម និងកម្ពុជា ដោយសារតែគោលនយោបាយវៀតណាម ចង់បោសសម្អាតបំបាត់ពូជសាសន៍ខ្មែរ។

**នួន ជា** បានរិះគន់ការិយាល័យសហចៅក្រមស៊ើបអង្កេតថា ការិយាល័យនេះស្វែងរកតែភស្តុតាងដាក់បន្ទុកប៉ុណ្ណោះ ដូច្នេះ វាធ្វើឲ្យដំណើរការនីតិវិធីមានភាពលម្អៀង។ គាត់បានបញ្ចប់សេចក្តីថ្លែងការណ៍ដោយស្នើឲ្យអង្គជំនុំជម្រះបន្តពិភាក្សាលើប្រវត្តិសាស្ត្ររបស់កម្ពុជាប្រជាធិបតេយ្យ និង ស្តាប់សក្ខីកម្មសាក្សីបន្ថែម ដូចជា ប្រជាជននៅទីក្រុងភ្នំពេញ មុនពេលដួលរលំបក្សកម្ពុជាប្រជាធិបតេយ្យ និងអាមេរិកាំងដែលអាចបំភ្លឺពីការបំផ្លិចបំផ្លាញយ៉ាងសន្ធាប់ដែលបង្កដោយការទម្លាក់គ្រាប់បែករបស់អាមេរិក។ គាត់ក៏បានស្នើសុំអង្គជំនុំជម្រះអនុញ្ញាតឲ្យគាត់បង្ហាញឯកសារបន្ថែមរហូតដល់បញ្ចប់កិច្ចដំណើរការសវនាការ។ **នួន ជា** បានបន្ថែមថា ប្រសិនបើអង្គជំនុំជម្រះបដិសេធនឹងសំណើនេះ គាត់នឹងអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតប។

អង្គជំនុំជម្រះបានរំឭក **នួន ជា** ថា សំណើមួយចំនួនរបស់គាត់ត្រូវបានពិចារណាហើយ ចំណែកឯសំណើមួយចំនួនទៀត កំពុងស្ថិតក្នុងការពិចារណា។ វាច្បាស់ណាស់ថា ការពិភាក្សាលើប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ មិនត្រូវបានឆ្លើយតបទេ នៅពេលប្រធានអង្គជំនុំជម្រះ **និល ណុន** បានចោទសួរ **នួន ជា** ថាតើគាត់ត្រៀមខ្លួនក្នុងការឆ្លើយតបសំណួរពាក់ព័ន្ធនឹងសវនាការផ្នែកទី២។ នៅពេលនោះ **នួន ជា** បានប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតប និងថ្លែងថា គាត់គួរតែទទួលបានឱកាសពន្យល់អំពីស្ថានការណ៍ជុំវិញការជម្លៀសប្រជាជនកម្ពុជា។

ជាថ្មីម្តងទៀត អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អង្គជំនុំជម្រះមិនបានត្រៀមទុកជាមុនក្នុងការកោះអញ្ជើញសាក្សីបម្រុង ទោះបីជាករណីនេះមិនមែនជាលើកដំបូង ដែលជនជាប់ចោទបានអនុវត្តសិទ្ធិនៅស្ងៀមក្នុងពេលសវនាការ។ តាមរយៈបទពិសោធន៍ពីសប្តាហ៍មុនៗ អង្គជំនុំជម្រះគួរតែដឹងអំពីសក្តានុភាពនៃការពន្យារពេល។ ទោះបីជាយ៉ាងណា តុលាការគ្មានជម្រើសអ្វីក្រៅពីផ្អាកសវនាការនៅព្រឹកនោះទេ។ អង្គជំនុំជម្រះ បានប្រកាសចាប់ផ្តើមស្តាប់សក្ខីកម្មរបស់សាក្សី **ឌុច** នៅរសៀលថ្ងៃនោះ ដែលជំនួសឲ្យកាលវិភាគរៀបចំថ្ងៃអង្គារ។

## ខ. សេចក្តីសង្ខេបសក្ខីកម្មរបស់ កាំង ហ្គេចអ៊ាវ

**ឌុច** គឺជាលេខាធិការរបស់មន្ទីរសន្តិសុខស-២១ ដែលគេស្គាល់ថាជាឧបករណ៍ស្ទូចម្លើយ និងសម្លាប់មនុស្សរបស់បក្សកម្ពុជាប្រជាធិបតេយ្យ។ សកម្មភាពដែលសាក្សីប្រព្រឹត្តនៅមន្ទីរនេះ គាត់ត្រូវបានតុលាការកាត់ទោស និងដាក់ពន្ធនាគារអស់មួយជីវិត ចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ នៅក្នុងសំណុំរឿង០០២ **ឌុច** ត្រឡប់មកវិញ ប៉ុន្តែមិនមែនក្នុងនាមជាជនជាប់ចោទទេ គឺជាសាក្សីដ៏សំខាន់មួយរូប ដែលអាចបំភ្លឺពីស្ថានភាពខ្មៅអាប់អួរនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា។ សហព្រះរាជអាជ្ញាបានចោទសួរ **ឌុច** អំពី (១) ការជ្រើសរើសចូលបក្ស និងទំនាក់ទំនងជិតស្និទជាមួយបក្សកុម្មុយនីស្តកម្ពុជា (២) ការងារគាត់ក្នុងនាមជាសមាជិកបក្ស (៣) ការឃាត់ខ្លួនគាត់នៅឆ្នាំ១៩៩៩ និង (៤) មនោគមន៍វិជ្ជារបស់បក្ស និង (៥) គោលនយោបាយបក្ស។ យោងទៅលើចរិតទទួលខុសត្រូវខ្ពស់របស់គាត់ **ឌុច** បានផ្តល់ចម្លើយ

យ៉ាងលម្អិតចំពោះសំណួរទាំងឡាយ និងថែមទាំងអះអាងដោយលើកជាឧទាហរណ៍បញ្ជាក់ដូចដែលគាត់បានធ្វើនៅក្នុងសវនាការខ្លួននៅចំពោះមុខ អ.វ.ត.ក។

ពេញមួយសប្តាហ៍នេះ **ឌុច** បានថ្លែងជាដដែលថា ក្នុងអំឡុងពេលដែលគាត់គឺជាប្រធានមន្ទីរស-២១ គាត់បានទទួលបញ្ជា និងរាយការណ៍ផ្ទាល់ទៅ **នួន ជា**។ គាត់ក៏បានបន្ថែមព័ត៌មានមុនថា នៅពេលដែល **ប៉ុល ពត** មានជម្ងឺ គឺមានការប្រកាសជាសាធារណៈតែងតាំង **នួន ជា** ជានាយករដ្ឋមន្ត្រីជំនួស។

## *ខ.១. សមាជិកភាពរបស់បក្សកុម្មុយនីស្តកម្ពុជា និងការទទួលខុសត្រូវ*

ព្រះរាជអាជ្ញា **សេង ប៊ុនឃាង** បានចាប់ផ្តើមសួរដេញដោល **ឌុច** ដោយសំណួរដែលមានការណែនាំពាក់ព័ន្ធនឹងសាវតាសាក្សី ដូចជា ការសិក្សារបស់គាត់នៅសាលាព្រះស៊ីសុវត្ថិ និងការងារជាគ្រូបង្រៀនគណិតវិទ្យា។ បន្ទាប់មក សហព្រះរាជអាជ្ញាជាតិបានផ្តោតសំខាន់ទៅលើការចូលរួមបក្សកុម្មុយនីស្តកម្ពុជា។ នៅឆ្នាំ ១៩៦៤ គាត់បានចូលរួមចលនាបដិវត្តន៍ និងបានសិក្សាពីបដិវត្តន៍តាមការអានសៀវភៅ និងមនោគមន៍វិជ្ជាកុម្មុយនីស្ត។ ប្រាំមួយឆ្នាំក្រោយមក គាត់បានក្លាយជាសកម្មជនដ៏សកម្មរបស់បក្សកុម្មុយនីស្តនៅក្នុងតំបន់រំដោះ។ **ឌុច** បានចាប់ផ្តើមសិក្សាពីមនោគមន៍របស់បក្សកុម្មុយនីស្តកម្ពុជា ដូចមានចែងនៅក្នុងលក្ខន្តិកៈរបស់បក្ស រួមមាន ផែនការយុទ្ធសាស្ត្រ[1] និងមាគ៌ាយុទ្ធវិធី[2] (សង្គ្រាមកងឈ្លប) និងឯកសាររបស់បក្សអំពីការតស៊ូប្រឆាំងវណ្ណៈភាព។ គាត់បានអះអាងថា នាពេលនោះ គាត់បានឮពីឈ្មោះ **ខៀវ សំផន** និង **អៀង សារី** ប៉ុន្តែមិនធ្លាប់ជួបពួកគាត់ផ្ទាល់ទេ។ នៅពេលនោះ គាត់មិនដែលឮពី **ប៉ុល ពត** ឡើយ។

**ការតែងតាំងការងារនៅមន្ទីរសន្តិបាលម-១៣** ៖ បន្ទាប់ពីសួរសំណួរមួយចំនួនពាក់ព័ន្ធនឹងការងាររបស់ **ឌុច** នៅតំបន់រំដោះ សហព្រះរាជអាជ្ញាបានចាប់ផ្តើមចោទសួរសំណួរអំពីទំនាក់ទំនងរបស់ **ឌុច** នៅក្នុងការងារសន្តិសុខ។ **ឌុច** បានពន្យល់ថា នៅឆ្នាំ១៩៧១ គាត់បានទទួលតំណែងជាប្រធានមន្ទីរសន្តិបាលម-១៣ (មន្ទីរម-១៣) ដែលតែងតាំងដោយ ***វន វេត*** (ជាសមាជិកគណៈមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជា)។ ក្នុងនាមជាសមាជិកបក្ស **ឌុច** បានផ្តល់សក្ខីកម្មថា គាត់គ្មានជម្រើសអ្វីក្រៅពីទទួលយកតួនាទីនេះទេ។ មន្ទីរម-១៣ គឺជាមន្ទីរឃុំឃាំងសម្រាប់ដាក់ទាហាន និងប្រជាជនដែលបក្សចោទថា ជាគិញ *"ខ្មាំង"*។

**ឌុច** បានបន្តថា ***វន វេត*** បានណែនាំគាត់ពីរបៀបសួរចម្លើយអ្នកទោស ហើយគាត់ក៏បានបង្វឹកកម្មាភិបាលថ្នាក់ក្រោមអំពីបច្ចេកទេសទាំងនេះ។ ក្រោមការគ្រប់គ្រងរបស់ ***វន វេត*** នៅមន្ទីរម-១៣ ទាំង **ឌុច** និងអ្នកផ្សេងទៀត បានធ្វើទារុណកម្មអ្នកទោសដោយ ការវាយតប ឆក់ខ្សែភ្លើង ជ្រមុជទឹក និងច្រកមុខក្នុងថង់ប្លាស្ទិកធ្វើឲ្យថប់ដង្ហើម។ **ឌុច** បានពន្យល់ថា បច្ចេកទេសទាំងអស់នេះ គឺមានដើមកំណើតមកពីចលនាឥស្សរៈ ហើយអនុវត្តជាទូទៅ។ ក្រោយមក **ឌុច** បានប្រើប្រាស់វិធីសាស្ត្រទាំងនេះនៅមន្ទីរស-២១ និងមន្ទីរស-២៤។ សាក្សីបានបញ្ជាក់ថា គាត់ទទួលបានបញ្ជាពី ***វន វេត*** ក្នុងការកម្ទេចអ្នកទោស។

**សុន សេន** មកជំនួសតំណែង **វន វេត** នៅដើមឆ្នាំ១៩៧៤។ **ឌុច** បានថ្លែងថា គាត់ជួបជាមួយថ្នាក់លើ (មេថ្មី) នៅវគ្គសិក្សាប្រចាំខែ និងកិច្ចពិភាក្សាពិសេសដែលបានរៀបចំឡើង។ នៅខែមករា ឆ្នាំ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាបានបញ្ឈប់ប្រតិបត្តិការរបស់មន្ទីរម-១៣។ **ឌុច** ប៉ាន់ប្រមាណថា អ្នកទោសពី ២០០ ទៅ ៣០០នាក់ ត្រូវបានសម្លាប់នៅមន្ទីរម-១៣ ប៉ុន្តែគាត់មិនបានបកស្រាយថា តើនៅពេលណា ឬស្ថិតនៅក្រោមការគ្រប់គ្រងរបស់នរណាទេ។ **ឌុច** បានអះអាងថា គាត់បានទុកជីវិតមនុស្សមួយចំនួន ព្រោះគាត់ជឿជាក់ថាអ្នកទាំងនោះមិនបានប្រព្រឹត្តកំហុសអ្វីទេ។ អ្នកទោសប្រមាណជា ៥០ ទៅ ១០០នាក់ ត្រូវបានដោះលែងឲ្យរួចខ្លួន នៅក្នុងពេល និងក្រោយពេលប្រតិបត្តិការរបស់មន្ទីរម-១៣។

**ការបង្កើតមន្ទីរស-២១ និងតួនាទីជាអ្នកគ្រប់គ្រង ៖** យោងតាមសាក្សី **ឌុច** បានឲ្យដឹងថា **សុន សន** បានណែនាំគាត់ឲ្យចូលរួមវគ្គបណ្ដុះបណ្ដាលនៅទីក្រុងភ្នំពេញនៅខែមិថុនា ឆ្នាំ១៩៧៥។ នាពេលនោះ គាត់បានជួបជាមួយមិត្ត **ណាត** ដែលជាអតីតប្រធានបុគ្គលិកនៅក្នុងរដ្ឋាភិបាល **លន់ នល់**។ កម្មាភិបាល **ណាត** មានមុខងាររៀបចំបង្កើតមន្ទីរសន្តិសុខស-២១ (ឬហៅថា ទួលស្លែង) ដែលជាមន្ទីរសន្តិសុខរបស់របបខ្មែរក្រហម។ **សុន សេន** បានតែងតាំងសាក្សី **ឌុច** ជាអនុប្រធានប្រចាំមន្ទីរស-២១ និងបានណែនាំគាត់ឲ្យយកកម្លាំងពីមន្ទីរម-១៣ មកធ្វើការនៅមន្ទីរសន្តិសុខថ្មីនេះ។ យោងតាមសាក្សី **ឌុច** បានឲ្យដឹងថា គោលបំណងនៃការបង្កើតមន្ទីរសន្តិសុខស-២១ គឺដើម្បីទាញយកចម្លើយសារភាពពីអ្នកទោសតាមរយៈការធ្វើទារុណកម្ម។ សាក្សីបានបន្តថា គោលនយោបាយបក្ស គឺកម្ទេចអ្នកទោសទាំងអស់។

នៅក្នុងសក្ខីកម្មរបស់គាត់ **ឌុច** បានរៀបរាប់អំពីរបៀបដែលគាត់ចូលកាន់តំណែងជាប្រធានមន្ទីរស-២១ ជំនួសកម្មាភិបាល **ណាត** នៅខែមីនា ឆ្នាំ១៩៧៦ គឺក្រោមការបញ្ជារបស់ **សុន សេន**។ ក្នុងនាមជាប្រធានមន្ទីរថ្មី សាក្សី **ឌុច** បានថ្លែងថា គាត់រាយការណ៍ជាប្រចាំទៅ **សុន សេន**។ សំខាន់ជាងនេះ ចាប់តាំងពីមន្ទីរស-២១ បង្កើតទៅជាកងវរសេនាធំឯករាជ្យ **ឌុច** ត្រូវរាយការណ៍ទៅមេដឹកនាំផ្ទាល់ ដែលជាសមាជិកគណៈមជ្ឈិម ដោយមិនចាំបាច់ឆ្លងកាត់អ្នកកណ្ដាល។ មន្ទីរនេះរៀបចំឡើង គឺមានលក្ខណៈពិសេស និងលាក់ការសម្ងាត់របស់របបខ្មែរក្រហម។ ក្នុងនាមជាប្រធានមន្ទីរស-២១ **ឌុច** ត្រូវអានចម្លើយសារភាពដែលបានពីការធ្វើទារុណកម្ម និងសង្ខេបចម្លើយសារភាពទាំងនោះ។ បន្ទាប់មក គាត់ត្រូវរាយការណ៍ទៅ **សុន សេន** ចំពោះចម្លើយសារភាពទាំងនោះ។ គាត់ក៏បានចូលរួមវគ្គបណ្ដុះបណ្ដាលប្រចាំឆ្នាំ ស្ដីពីគោលនយោបាយបក្ស។ **ឌុច** បានអះអាងថា ការងាររបស់គាត់ត្រូវបានបញ្ចប់ គឺនៅពេលដែលកងទ័ពវៀតណាមវាយលុកចូលដល់ទីក្រុងភ្នំពេញ នៅខែមករា ឆ្នាំ១៩៧៩។

**ខ្សែជីវិតបន្ទាប់ពីឆ្នាំ១៩៧៩ ៖** សាក្សី **ឌុច** នៅតែជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា ទោះបីជា គាត់ចាកចេញពីមន្ទីរស-២១ តាំងពីឆ្នាំ១៩៧៩ ក៏ដោយ។ នៅក្នុងឆ្នាំ១៩៨៦ គាត់បានធ្វើដំណើរទៅប្រទេសចិនដើម្បីបង្រៀនភាសាខ្មែរដល់និស្សិតនៅទីនោះ។ ពីរឆ្នាំក្រោយមក គាត់បានត្រឡប់មកប្រទេសកម្ពុជាវិញ និង

បានសរសេរសៀវភៅកម្មវិធីសិក្សាឲ្យថ្នាក់បឋមសិក្សា ដែលគ្រប់គ្រងដោយលោកស្រី **យន់ យ៉ាត** (ភរិយារបស់ **សុន សេន**)។ ក្រោយមក **ប៉ុល ពត** បានចាត់តាំងគាត់ឲ្យធ្វើការនៅផ្នែកសេដ្ឋកិច្ចនៅតំបន់ជនបទ។ សាក្សីក៏បានក្លាយជាគ្រូបង្រៀននៅក្នុងនាយកដ្ឋានអប់រំ ស្រុកសំឡូត ខេត្តបាត់ដំបង រហូតដល់គាត់ត្រូវបានចាប់ខ្លួននៅឆ្នាំ១៩៩៩។

## *ខ.២. មនោគមន៍វិជ្ជា និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា*

បន្ទាប់ពី **ឌុច** បានផ្តល់សក្ខីកម្មអំពីបទពិសោធន៍របស់គាត់ពាក់ព័ន្ធនឹងបក្សកុម្មុយនីស្តកម្ពុជា ភាគីសហព្រះរាជអាជ្ញាបានចាប់ផ្តើមសួរដេញដោលគាត់ អំពីមនោគមន៍វិជ្ជា និង ការរីកសាយភាយនៃទស្សនៈនេះ ព្រមទាំងគោលនយោបាយជាក់លាក់មួយចំនួន ដែលចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ។

**មនោគមន៍វិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា ៖** នៅពេលដែលមានសំណួរពាក់ព័ន្ធនឹងមនោគមន៍វិជ្ជា និងគោលបំណងចម្បងៗរបស់កម្ពុជាប្រជាធិបតេយ្យ សាក្សី **ឌុច** បានពន្យល់ថា មុនឆ្នាំ១៩៧០ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាមានជំនឿថា ប្រជាជនត្រូវចេះរំដោះខ្លួនឯង និងប្រយុទ្ធប្រឆាំងនឹងពួកមូលធននិយម និងសមាសភាព "ប្រតិកិរិយា" ក្នុងសង្គម។ ពួកគេក៏មានជំនឿថា កសិករគួរតែមានដីស្រែធ្វើស្រែចម្ការ។ ក្រោយឆ្នាំ១៩៧០ សាក្សី **ឌុច** បានរៀបរាប់ថា បក្សកុម្មុយនីស្តកម្ពុជា បានផ្តោតសំខាន់លើកិច្ចការពារទឹកដី និងកសាងប្រទេសជំនួសវិញ។

សាក្សីក៏បានចង្អុលបង្ហាញថា មិនមែនតែបក្សកុម្មុយនីស្តកម្ពុជាទេដែលប្រើប្រាស់អំពើហិង្សា ដើម្បីឈានឆ្ពោះទៅដល់គោលដៅរបស់ខ្លួន វាគឺជា *"និន្នាការទូទៅ"* ដែលអនុវត្តទូទាំងពិភពលោក។ **ឌុច** បានថ្លែងថា ការប្រើប្រាស់កម្លាំងប្រដាប់អាវុធត្រូវបានហាមឃាត់ បន្ទាប់ពីមហាសន្និបាតលើកទី២០ របស់បក្សកុម្មុយនីស្តសូវៀត។ នៅពេលនោះ បក្សបានសម្រេចថា នឹងមិនប្រើកម្លាំងទ័ពទេ ប៉ុន្តែចំពោះអ្នកបដិវត្តន៍លទ្ធិម៉ាក្សលេនីន ច្បាស់ណាស់ថា ពួកគេនឹងប្រើកម្លាំងទ័ព។

នៅក្នុងសក្ខីកម្មដំបូង សាក្សី **ឌុច** បានថ្លែងថា បក្សមិនដែលលើកឡើងពីសាសនាព្រះពុទ្ធ ឬវប្បធម៌ខ្មែរទេ។ សាក្សីបានចង្អុលបង្ហាញថា គោលគំនិតចម្បងរបស់បក្ស គឺដើម្បីធានាសាមគ្គីភាព និងការរួបរួមជាតិ ហើយ *"ពួកគេធ្វើអ្វីគ្រប់យ៉ាង ដើម្បីបម្រើកម្មករ និងវណ្ណៈសង្គម"*។ សមាជិកបក្ស គឺមានកាតព្វកិច្ចក្នុងការបម្រើ គោរព និងស្រឡាញ់ប្រជាជនឲ្យអស់ពីចិត្តពីថ្លើម។ មនុស្សគ្រប់រូបត្រូវរៀនរស់នៅជាមួយគ្នា ក្នុងស្មារតីស្មើភាព និងគោរពគ្នាទៅវិញទៅមក។ ទោះបីជាយ៉ាងណា នៅក្នុងសវនាការក្រោយៗ **ឌុច** បានផ្តល់សក្ខីកម្មថា បក្សកុម្មុយនីស្តកម្ពុជាបានបំបិទលែងឲ្យមានការគោរពសាសនា និងឪពុកម្តាយ *"ម៉ែឪបង្កើតមនុស្សបានតែម្នាក់ អង្គការបដិវត្តន៍រំដោះមនុស្សបានមួយនគរ"*។ លើសពីនេះ បក្សអប់រំថា គ្រប់គ្នាត្រូវតែហ៊ានសងសឹកប្រឆាំងតបតនឹងខ្មាំង និងធ្វើតាមការសម្រេចរបស់បក្សគ្រប់យ៉ាង សូម្បីតែការផ្តន្ទាទោសលើខ្លួន។

**ការផ្សព្វផ្សាយមនោគមន៍វិជ្ជា និងគោលនយោបាយបក្ស ៖** ការផ្សព្វផ្សាយមនោគមន៍វិជ្ជា និងគោលនយោបាយបក្ស ត្រូវបានធ្វើឡើងតាមប្រព័ន្ធសិក្សារៀនសូត្រ។ យោងតាម **ឌុច** បានឲ្យដឹងថា ថ្នាក់ដឹកនាំម្នាក់ៗមាននាទីអប់រំអ្នកនៅក្រោមបង្គាប់ អំពីមនោគមន៍វិជ្ជា និងគោលនយោបាយផ្សេងៗរបស់បក្ស។ ចំណែកឯ លេខាធិការភូមិភាគនីមួយៗ ត្រូវចូលរួមវគ្គសិក្សារៀនសូត្រប្រចាំឆ្នាំជាមួយ **ប៉ុល ពត** ដើម្បីពិភាក្សាអំពីស្ថានភាពនៅតាមសមរភូមិ និងរបៀបដែលពួកគេអាចរៀបចំខ្លួនឯង ទាំងផ្លូវកាយ និងផ្លូវចិត្ត។ បញ្ហាសុជីវធម៌ និងរចនាសម្ព័ន្ធផ្សេងៗ ដូចជា *«ការប្រជុំជីវភាពបក្ស»* ក៏ត្រូវបានលើកឡើងនៅក្នុងវគ្គសិក្សារៀនសូត្រនេះដែរ។ ឯកសារប្រើប្រាស់នៅក្នុងវគ្គរៀនសូត្រ រួមមាន ៖ លក្ខន្តិកៈបក្ស ផែនការយុទ្ធសាស្ត្រ និង មាគ៌ាយុទ្ធវិធី ក៏ដូចជា ទស្សនាវដ្តី *ទង់បដិវត្តន៍* និង ឯកសារផ្សេងៗ។

**កិច្ចប្រជុំជីវភាពបក្ស ប្រជុំទិតៀន និងស្វ័យទិតៀន ៖** ដោយសារតែជាមធ្យោបាយមួយ ដើម្បីឲ្យបក្សអាចគ្រប់គ្រងបញ្ហាសីលធម៌របស់ប្រជាជន និងការគោរពចំពោះបក្ស **ឌុច** បានពន្យល់ថា មនុស្សគ្រប់រូបត្រូវអនុវត្តឲ្យបានខ្ជាប់ខ្ជួននូវកិច្ចប្រជុំ *«ទិតៀន និង ស្វ័យទិតៀន»*។ កិច្ចប្រជុំនេះ ធ្វើឡើងជារៀងរាល់ថ្ងៃ ដូច្នេះមនុស្សគ្រប់រូបត្រូវទិតៀនគ្នាទៅវិញទៅមក ដោយចំពោះ ឬដោយសម្ងាត់ ប្រសិនបើរកឃើញថា មានកំហុស ឬប្រព្រឹត្តអំពើមិនសមរម្យ។ បក្សកុម្មុយនីស្តកម្ពុជាក៏មានវគ្គ *«ស្វ័យទិតៀន»* ឬ ហៅថា *«ប្រជុំជីវភាពបក្ស»* ដែលសមាជិកគ្រប់រូបត្រូវតែចូលរួមជាដាច់ខាត។ សាក្សី **ឌុច** បានពន្យល់ថា កិច្ចប្រជុំនេះ គឺជាមធ្យោបាយអប់រំកសាងខ្លួន កែប្រែកំហុស និងប្តេជ្ញាចិត្តចូលរួមកសាងបក្ស។ ជាទូទៅ រូបភាពនៃកិច្ចប្រជុំ គឺថា សមាជិកនៃអង្គប្រជុំលើកឡើងពី *«កំហុសតូចតាច»* ជាសាធារណៈ ប៉ុន្តែចំពោះបញ្ហាធ្ងន់ធ្ងរ គឺពិភាក្សាជាលក្ខណៈដោយឡែកជាមួយអ្នកប្រព្រឹត្តកំហុស។ សាក្សី **ឌុច** បានថ្លែងថា គាត់បានពិភាក្សាជាមួយមិត្ត **ណាត** ជាលក្ខណៈតទល់ (តាមស្មាន គឺពិភាក្សាអំពីការប្រព្រឹត្តបទល្មើស) មុនពេលអតីតប្រធានមន្ទីរស-២១រូបនេះ ត្រូវបានចាប់ខ្លួន និងកម្ទេច។ ការប្រព្រឹត្តកំហុសធ្ងន់ធ្ងរ អាចនឹងត្រូវបានរាយការណ៍ទៅថ្នាក់លើ ហើយបើរកឃើញថា មានកំហុស សមាជិករូបនោះនឹងត្រូវដកចេញពីបក្ស។ សាក្សី **ឌុច** បានបន្តថា ប្រសិនបើសកម្មភាពនោះជាអំពើឧក្រិដ្ឋ ជោគវាសនារបស់បុគ្គលនោះ គឺសម្រេចដោយប្រជាជន។ ទស្សនៈនៃការទិតៀន គឺជាគោលការណ៍ដ៏សំខាន់ដែលមានចែងនៅក្នុងលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា។

**គោលនយោបាយនៃការបង្ខំជម្លៀសប្រជាជន ៖** បក្សកុម្មុយនីស្តកម្ពុជាបានអនុម័តយុទ្ធសាស្ត្រសង្គ្រាម *«ការដណ្តើមប្រជាជនពីខ្មាំង»* ដែលមានន័យថា *«នៅពេលវ៉ៃនៅទីតាំងណា គឺត្រូវជម្លៀសប្រជាជនចេញពីទីនោះ»* ពោលគឺត្រូវយកប្រជាជនចេញពីការត្រួតត្រារបស់សត្រូវ ដើម្បីឲ្យសត្រូវទន់ខ្សោយ ឬបាត់បង់កម្លាំង។ សាក្សី **ឌុច** បានបន្តថា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គាត់ស្ថិតនៅក្នុង *«តំបន់ពិសេស»* (សាក្សីមិនបានបញ្ជាក់ឈ្មោះតំបន់នោះទេ) ហើយគាត់ទើបតែដឹងនៅពេលក្រោយ ស្តីពីគោលនយោបាយជម្លៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំនានា តាមរយៈទស្សនាវដ្តី *ទង់បដិវត្តន៍*។ ទោះបីជាយ៉ាងណា គាត់មិនដឹងពី

ហេតុផលនៃគោលនយោបាយ ឬការអនុវត្តនេះទេ។ **ឌុច** បានផ្តល់សក្ខីកម្មថា ប្អូនថ្លៃរបស់គាត់បានប្រាប់គាត់ថា ផែនការជម្លៀសប្រជាជនកំពុងតែងអនុវត្តគ្រប់ទិសទី ៖ *គេមានបែងចែកហើយស្រេច។ អ្នកណាជិះឡានគឺគេយកទៅកម្ទេច។ អ្នកណាដែលគេឲ្យដើរ គឺនៅរស់*។ ក្នុងអំឡុងនៃការជម្លៀស សមាជិកគ្រួសារត្រូវបានគេបំបែកចេញពីគ្នា និងបានបញ្ជូនទៅសហករណ៍ផ្សេងៗគ្នា។

**គោលនយោបាយស្តីអំពីសហករណ៍ និងការបង្ខំឲ្យធ្វើការ** ៖ សាក្សី **ឌុច** បានពន្យល់ថា គោលបំណងចម្បងរបស់របបនេះ គឺឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន តាមរយៈការបង្កើតសហករណ៍។ នៅឆ្នាំ១៩៧២ **សុន សេន** បានបង្កើតសហករណ៍មួយនៅព្រៃស សម្រាប់អប់រំកែប្រែសមាជិកបក្ស និងយោធា (ដែលជាគម្រោងសាកល្បងដំបូង)។ បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ឯកសារបក្សមួយបានលើកឡើងថា សហករណ៍ត្រូវតែបង្កើត និងអនុវត្តទូទាំងប្រទេស ដោយសារតែវណ្ណៈ។ សហករណ៍នីមួយៗគ្រប់គ្រងដោយលេខាធិការមួយរូប និងគណៈកម្មាធិការឃុំ។ យោងតាមសាក្សី **ឌុច** បានឲ្យដឹងថា មិនមានឯកសារផ្លូវការណាមួយនិយាយពីផែនការផលិតស្រូវអង្ករទេ។ នៅឆ្នាំ១៩៧៦ បក្សបានប្រកាសតាមវិទ្យុថា ទិន្នផលស្រូវត្រូវបង្កើនឲ្យបាន ៣តោនក្នុង១ហិចតា ក្នុងមួយរដូវ។ ពាក់ព័ន្ធនឹងសេវាថែទាំសុខភាព ឬថ្នាំសង្កូវនៅក្នុងសហករណ៍ **ឌុច** បានឲ្យដឹងថា ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បុគ្គលិកពេទ្យទាំងអស់ត្រូវបានជម្លៀសចេញ និងបំបែកឲ្យទៅនៅតាមទីជនបទ។ ដូចនេះ មានតែ *"ថ្នាំខ្មែរបុរាណ"* ដែលអនុញ្ញាតឲ្យប្រើប្រាស់ និងអាចស្វែករកបាន។

**គោលនយោបាយបក្សអំពីសត្រូវ** ៖ នៅក្នុងសក្ខីកម្មពីរថ្ងៃដំបូង **ឌុច** បានផ្តល់ព័ត៌មានទូទៅអំពីសត្រូវក្នុងអំឡុងពេលដែលគាត់ទទួលបន្ទុកនៅមន្ទីរម-១៣ និងមន្ទីរស-២១។ ការចាត់ចែងនេះ រួមមាន៖ មនុស្សដែលជ្រៀតចូល ឬឆ្លងកាត់តំបន់រំដោះ និងបានចូលដល់មូលដ្ឋាន ប៉ូលីស និងទាហាននៃរបប **លន់ នល់** ក្រុមបញ្ញវន្ត កម្មកររោងចក្រ អ្នកនេសាទជនជាតិថៃ ក្រុមជនជាតិភាគតិចតស្លាម ការចាប់ខ្លួនបុគ្គលដោយហេតុផលជាក់លាក់ (ដូចជា ហេតុការណ៍បាញ់ប្រហារក្នុងវត្តមួយ) ព្រះសង្ឃ ឬអាចារ្យ និងប្រជាជនដែលទទួលការអប់រំនៅប្រទេសវៀតណាម។ នៅពេលការបោសសម្អាតផ្ទៃក្នុងរីករាលកាន់តែខ្លាំងនៅដើមឆ្នាំ១៩៧៧ កម្មាភិបាលមកពីកងពល និងភូមិភាគនានា ហើយសូម្បីតែសមាជិកថ្នាក់ដឹកនាំបក្សក៏ត្រូវចាប់ខ្លួនដោយចោទថាជាគិញ។ ពួកគេត្រូវទទួលរងទារុណកម្មយ៉ាងធ្ងន់ធ្ងរនៅពេលសួរចម្លើយ នៅទីបំផុត ពួកគេត្រូវយកទៅកម្ទេច។ នៅពេលមានសំណួរអំពីមូលហេតុនៃការកម្ទេចខ្មាំង **ឌុច** បានបដិសេធមិនធ្វើការបរិយាយលើករណីនេះទេ។ គាត់បានផ្តល់សក្ខីកម្មថា *"បញ្ជាកម្ទេច គឺជាក្រិត្យក្រម ឬគោលនយោបាយបក្ស។ មនុស្សដែលចាប់ចូលហើយ គឺត្រូវតែកម្ទេច"*។ សាក្សីបានបន្ថែមថា គោលនយោបាយនេះ គ្មាននរណាហ៊ានតតាំង ឬជំទាស់ទេ។ យោងតាម **ឌុច** បានឲ្យដឹងថា គាត់បានទទួលព័ត៌មានថាតើនរណាចាត់ទុកជាសត្រូវពី **សុន**

**សេន** និង **នួន ជា**។ គោលនយោបាយនេះ អនុវត្តនៅគ្រប់ទីកន្លែងទូទាំងប្រទេសកម្ពុជា ជាពិសេស នៅក្នុងមន្ទីរសន្តិសុខទាំង ១៩៦។

**គោលនយោបាយស្តីអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ៖** ព្រះរាជអាជ្ញា **សេង ប៊ុនឃាង** បានសួរដេញដោលអំពីការចោទប្រកាន់ពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងអំពីអាពាហ៍ពិពាហ៍របស់ **ឌុច** ផ្ទាល់។ **ឌុច** បានឆ្លើយប្រាប់ថា គាត់មានសេរីភាពក្នុងការជ្រើសរើសភរិយារបស់ខ្លួន ប៉ុន្តែត្រូវសុំការអនុញ្ញាតពី **តាម៉ុក** ក្នុងការ *"រៀបចំ"* ពិធីអាពាហ៍ពិពាហ៍។ ទោះបីជាសាក្សីមិនបានផ្តល់ព័ត៌មានលម្អិតពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍របស់គាត់ក៏ដោយ ក៏គាត់បានពន្យល់ថា ជាទូទៅ ប្រសិនបើមានការពេញចិត្តគ្នាទៅវិញទៅមក បុរសស្ត្រីទាំងពីរអាចស្នើសុំរៀបការជាមួយគ្នាបាន ហើយសន្យាបង្កើតកូនចៅ។ ទោះបីជាយ៉ាងណា អាពាហ៍ពិពាហ៍រវាងប្រជាជនថ្មី (ជនភៀសខ្លួនពីទីក្រុង) និងប្រជាជនមូលដ្ឋាន ត្រូវបានហាមឃាត់ ដោយសារតែអតីតកាលរបស់ពួកគេ "មិនគួរឲ្យទុកចិត្ត"។

### *ខ.៣. គោលការណ៍ដាក់លាក់នៅក្នុងលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា*

ព្រះរាជអាជ្ញាអន្តរជាតិ **ស្មីត** បានសួរសំណួរដោយផ្តោតសំខាន់ទៅលើលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា។ ដើម្បីឲ្យយល់ដឹងកាន់ស៊ីជម្រៅអំពីប្រតិបត្តិការរបស់បក្សកុម្មុយនីស្តកម្ពុជា ព្រះរាជអាជ្ញា **ស្មីត** បានសុំឲ្យ **ឌុច** ពន្យល់វាក្យសព្ទបច្ចេកទេសមួយចំនួន ដែលមាននៅក្នុងគោលការណ៍លក្ខន្តិកៈឆ្នាំ១៩៧៦។

**ចលនាបដិវត្តន៍ប្រជាធិបតេយ្យទៅជាចលនាសង្គមនិយម ៖ ឌុច** បានថ្លែងថា បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាបានទទួលជោគជ័យលើ "បដិវត្តន៍ប្រជាធិបតេយ្យ" សាក្សីបានពន្យល់ថា នេះជាការជោគជ័យដ៏ធំដែលបណ្តេញពួកចក្រពត្តិនិយមចេញ និងជួយកសិករក្នុងការបង្កបង្កើនផល។ សាក្សីបានបន្តថា មិនយូរប៉ុន្មាន ក្រោយពីចលនានេះក្លាយទៅជា "បដិវត្តន៍សង្គមនិយម" ដែលជួយប្រជាជនក្នុងការបង្កបង្កើនផល និងចែកចាយទិន្នផលដល់អ្នកសង្គមនិយម។ សាក្សីបានរៀបរាប់ថា បក្សកុម្មុយនីស្តកម្ពុជា គឺជាបក្សដែលបានត្រួតត្រាផ្តាច់មុខ លើមន្ត្រីនគរបាល សេដ្ឋកិច្ច និងនយោបាយ។ **ឌុច** បានពន្យល់ថា គោលការណ៍ទី៤ នៃលក្ខន្តិកៈ បានបង្ហាញថា លទ្ធិម៉ាក្សលេនីន គឺត្រូវបានប្រើប្រាស់ជាមូលដ្ឋានគ្រឹះនៃមនោគមវិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា។ **ប៉ុល ពត** បានដាក់បញ្ចូលទ្រឹស្តីទាំងនេះនៅក្នុងគោលនយោបាយ និងមាគ៌ាយុទ្ធសាស្ត្ររបស់បក្សទៅតាមបរិបទប្រទេសកម្ពុជា។

***អំពីខ្មាំងសត្រូវ* ៖** សាក្សី **ឌុច** បានពន្យល់អំពីនិយមន័យនៃចំណាត់ថ្នាក់ខ្មាំងទាំងប្រាំប្រភេទ ដែលមានចែងនៅក្នុងគោលការណ៍ទី៤ រួមមាន ៖

- "ពួកអនុធន" គឺក្រុមដែលប្រើកម្លាំងបញ្ញា ចំណេះដឹង ដើម្បីចិញ្ចឹមជីវិត រួមមាន ក្រុមវេជ្ជបណ្ឌិត ក្រុមគ្រូបង្រៀនជាដើម។

- «ពួកមូលធន» គឺជាក្រុមអ្នកមានទ្រព្យធនច្រើន ហើយប្រើប្រាស់ធនធានទាំងនោះក្នុងការបណ្តាក់ទុន ដើម្បីប្រាក់ចំណេញ។
- «ពួកសក្តិភូមិ» គឺជាក្រុមមនុស្សអ្នកមានបុណ្យសក្តិ យកបុណ្យសក្តិទៅរកលុយ និងជាម្ចាស់ដី ដូចជា ខ្សែស្រឡាយ «រាជវង្សានុវង្ស»។
- «ពួកចក្រពត្តិ» គឺសំដៅទៅលើជនជាតិអាមេរិកាំង
- «ពួកប្រតិកិរិយា» សំដៅទៅលើអ្នកប្រឆាំងបដិវត្តន៍ រួមទាំង អ្នកប្រឆាំងសាសនា ដូចជា សាសនាប្រូតេស្តង់។

**ការចងរឹតមាគ៌ាមហាជន ៖** យោងតាមសាក្សី **ឌុច** បានឲ្យដឹងថា គោលការណ៍ទី៥ នៅក្នុងលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា បានចែងថា «បក្សកុម្មុយនីស្តកម្ពុជាប្រកាន់ខ្ជាប់ និងដាច់ខាត» ទៅតាមមាគ៌ាមហាជន។ គ្រប់ថ្នាក់ដឹកនាំទាំងអស់ត្រូវតែយល់ពីសុខទុក្ខ ក៏ដូចជា ត្រូវយកចិត្តទុកដាក់ចំពោះសុខមាលភាពសមាជិកក្រោមឱវាទ។ ទោះបីជាយ៉ាងណា នៅក្នុងសក្ខីកម្មរបស់ **ឌុច** បានឲ្យដឹងថា របបកម្ពុជាប្រជាធិបតេយ្យ គឺមិនបានអនុវត្តគោលការណ៍នេះទេ។

**ប្រជាធិបតេយ្យប្រមូលផ្តុំ ៖** ផ្អែកតាមសក្ខីកម្មរបស់ **ឌុច** បានឲ្យដឹងថា គោលការណ៍ «ប្រជាធិបតេយ្យប្រមូលផ្តុំ»[3] គឺមានន័យជាសាមញ្ញថា មតិភាគតិចត្រូវគោរពមតិភាគច្រើន។ តាមការអនុវត្តជាក់ស្តែង គឺថា បុគ្គលិកក្រោមឱវាទត្រូវគោរពមេដឹកនាំខ្លួន *«ថ្នាក់ក្រោមត្រូវគោរពថ្នាក់លើ»* ហើយមនុស្សរាល់គ្នាត្រូវគោរពអង្គការ (លេខាបក្ស)។ រាល់ការសម្រេចត្រូវធ្វើឡើងជាសមូហភាព មុនចេញសេចក្តីសម្រេចត្រូវមានការជជែកពិភាក្សា ប៉ុន្តែសេចក្តីសម្រេចចុងក្រោយ គឺសម្រេចដោយលេខាបក្ស។

សក្ខីកម្មរបស់សាក្សី **ឌុច** ពាក់ព័ន្ធនឹងគោលការណ៍បក្សកុម្មុយនីស្តកម្ពុជា មាគ៌ាទំនាក់ទំនង និងតួនាទីជាក់លាក់របស់ជនជាប់ចោទ នឹងត្រូវឆ្លើយបំភ្លឺនៅសប្តាហ៍ក្រោយ ពីសំណាក់ភាគីសហព្រះរាជអាជ្ញា ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះ និងក្រុមមេធាវីការពារក្តី។

## ផ្នែកទី ៣ ៖ បញ្ហាច្បាប់ និង នីតិវិធី

បញ្ហាច្បាប់ និងនីតិវិធីជាច្រើន បានកើតឡើងនៅក្នុងសវនាការនាសប្តាហ៍នេះ។ បញ្ហាមួយចំនួនបានលើកឡើងតាំងពីសប្តាហ៍មុន រួមមាន ផលលំបាកដែលអាចកើតមានដោយសារការប្រើប្រាស់សិទ្ធិនៅស្ងៀមរបស់ជនជាប់ចោទ។ ជាថ្មីម្តងទៀត សិទ្ធិជាមូលដ្ឋាននៃការជំនុំជម្រះក្តីដោយយុត្តិធម៌ ក៏បានក្លាយជាប្រធានបទនៃការជជែកពិភាក្សា នៅពេល **នួន ជា** បានបញ្ជាក់ថា គាត់នឹងប្រើប្រាស់សិទ្ធិនៅស្ងៀម ប្រសិនបើអង្គជំនុំជម្រះមិនអនុញ្ញាតតាមសំណើរបស់គាត់។ លើសពីនេះ ភាគីក៏បានជជែកបកស្រាយលើសិទ្ធិរបស់ជនជាប់ចោទក្នុងការប្រាស្រ័យទាក់ទងជាមួយមេធាវីខ្លួន ៖ ទីមួយ **នួន ជា** បានទាមទារសុំពិភាក្សាជាមួយមេធាវី នៅពេលគាត់កំពុងនៅក្នុងរង្វង់ក្រចកសេះ និងទីពីរ មេធាវី **ផេស្តមិន** ចង់ចូលមើលកូនក្តីខ្លួននៅពេលពិនិត្យសុខ

ភាព។ បញ្ហាផ្សេងទៀត រួមមាន ការបកស្រាយវិធានផ្ទៃក្នុងអំពី "ការពន្យារដំណើរការនីតិវិធី" និងការពិភាក្សាអំពីតួនាទីសាក្សីធម្មតា និងសាក្សីជំនាញ។

### ក. សិទ្ធិរបស់ជនជាប់ចោទនៅស្ងៀមមិនឆ្លើយតបសំណួរ

នៅពេលចាប់ផ្តើមសវនាការសប្តាហ៍នេះ **នួន ជា** បានប្រកាសសុំប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបចំនួនបីលើក។ គួរកត់សម្គាល់ថា មកដល់សប្តាហ៍នេះ **នួន ជា** គឺជាជនជាប់ចោទតែម្នាក់ដែលបានផ្តល់សក្ខីកម្ម និងឆ្លើយតបសំណួរនានាយ៉ាងសកម្មនៅក្នុងសំណុំរឿង០០២។ **នួន ជា** បានចាប់ផ្តើមប្រើប្រាស់សិទ្ធិនៅស្ងៀមជាលើកដំបូង នៅពេលអង្គជំនុំជម្រះបានបដិសេធមិនអនុញ្ញាតឲ្យគាត់ពិភាក្សា ឬសន្ទនាជាមួយមេធាវីខ្លួននៅព្រឹកថ្ងៃច័ន្ទ អំឡុងពេលដែលគាត់អានសេចក្តីថ្លែងការណ៍ជូនតុលាការ។ មេធាវី **ផេស្តមិន** ដែលជាមេធាវីការពារក្តីរបស់ **នួន ជា** បានជូនយោបល់ទៅកាន់តុលាការថា កូនក្តីខ្លួននឹងមិនឆ្លើយតបសំណួរឡើយ ប្រសិនបើអង្គជំនុំជម្រះមិនអនុញ្ញាតឲ្យគាត់បន្តការអានសេចក្តីថ្លែងការណ៍របស់គាត់។ អង្គជំនុំជម្រះ បានអនុញ្ញាតតាមសំណើទាំងពីររបស់ **នួន ជា**។ ជាក់ស្តែង នៅក្នុងសេចក្តីថ្លែងការណ៍របស់គាត់ គឺស្នើសុំឲ្យអង្គជំនុំជម្រះពិចារណាបន្តសវនាការផ្នែកទី១ឡើងវិញ ដែលពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ នៅពេលដែលតុលាការបដិសេធលើសំណើនេះ ជនជាប់ចោទ **នួន ជា** បានប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបជាលើកទីបីនៅព្រឹកនេះ។

បញ្ហានេះបានធ្វើឲ្យមានប្រតិកម្មយ៉ាងខ្លាំងពីសំណាក់សហព្រះរាជអាជ្ញា និងក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី។ មេធាវីនាំមុខ **អេលីហ្សាប៊ែត ស៊ីម៉ុនណូហ្វត** បានហៅយុទ្ធសាស្ត្ររបស់ **នួន ជា** ថាជា "ការស៊ីសំណូក" ជាពិសេស ចាប់តាំងពីដើមបណ្តឹងរដ្ឋប្បវេណីបានទាមទារឲ្យជនជាប់ចោទពន្យល់ពីព្រឹត្តិការណ៍ជុំវិញកម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងសំណើដាក់ទៅអង្គជំនុំជម្រះចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២ សហព្រះរាជអាជ្ញា បានបង្ហាញឲ្យឃើញថា **ខៀវ សំផន** បានបដិសេធមិនឆ្លើយសំណួរ បន្ទាប់ពីផ្តល់សេចក្តីថ្លែងការណ៍ដែលជះឥទ្ធិពលលើពីរករណី ៖ ទី១) មិនមែនជាការល្អទេ ដែលអង្គជំនុំជម្រះនឹងផ្តល់ទម្ងន់ដល់សក្ខីកម្មរបស់ **ខៀវ សំផន** និង ទី២) ការដកស្រង់យុត្តិសាស្ត្ររបស់តុលាការ *អាយ.ស៊ី.ស៊ី* និងតុលាការ*អាយ.ស៊ី.ធី.វ៉ាយ*[4] អង្គជំនុំជម្រះអាចនឹងទាញសេចក្តីសន្និដ្ឋានអវិជ្ជមានចេញពីការបដិសេធមិនឆ្លើយសំណួរ នៅពេលវាយតម្លៃលើភស្តុតាងដែលពាក់ព័ន្ធនឹងការចូលរួម និងការទទួលខុសត្រូវលើឧក្រិដ្ឋកម្ម។ ព្រះរាជអាជ្ញាអន្តរជាតិ **ខែល លីសាក់** បានលើកទឡ្ហីករណ៍ថា សំណើនេះគួរតែអនុវត្តចំពោះ **នួន ជា** ផងដែរ ដោយគាត់បានឆ្លើយសំណួរយ៉ាងសកម្មនៅក្នុងសវនាការផ្នែកទី១។ ជាការឆ្លើយតប ក្រុមមេធាវីការពារក្តីឲ្យ **ខៀវ សំផន** បានតតាំងថា ការអនុវត្តនៅ អ.វ.ត.ក និងតុលាការ *អាយ.ស៊ី.ធី.វ៉ាយ* ព្រមទាំងតុលាការ *អាយ.ស៊ី.ស៊ី* មិនអាចដូចគ្នាទេ ដោយសារតែតុលាការទាំងបីមានវិធានគ្រប់គ្រងផ្សេងគ្នា។[5]

គួរឲ្យកត់សម្គាល់ថា ជនជាប់ចោទទាំងបីប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយសំណួរនៅដំណាក់កាលផ្សេងគ្នា និងមានលក្ខខណ្ឌខុសៗគ្នា។ **អៀង សារី** បានបញ្ជាក់ថា គាត់ប្រើប្រាស់សិទ្ធិនៅស្ងៀមនៅក្នុងដំណើរការសវនាការទាំងមូល ដូច្នេះ គាត់នឹងមិនឆ្លើយសំណួរ ឬធ្វើអត្ថាធិប្បាយអ្វីទាំងអស់។ ចំពោះ **ខៀវ សំផន** បានប្រើប្រាស់សិទ្ធិនេះ ដោយមានលក្ខខណ្ឌថា គាត់អាចនឹងឆ្លើយសំណួរបន្ទាប់ពីសហព្រះរាជអាជ្ញាដាក់បង្ហាញភស្តុតាង។ ចំណែកឯ ជនជាប់ចោទ **នួន ជា** បានប្រកាសប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតប នៅពេលដែលសវនាការផ្នែកទី២បានចាប់ផ្តើម និងបានស្នើសុំឲ្យអង្គជំនុំជម្រះបន្តសវនាការអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យឡើងវិញ។ អង្គជំនុំជម្រះបានអនុញ្ញាតឲ្យជនជាប់ចោទទាំងអស់អានសេចក្តីថ្លែងការណ៍ខ្លួន នៅ "ថ្ងៃចាប់ផ្តើមសវនាការ"។ **ខៀវ សំផន** និង **នួន ជា** បានបង្ហាញឯកសារបន្ថែមនៅក្នុងពេលដំណើរការសវនាការ។[6]

មាត្រា៣៥ ថ្មី នៃច្បាប់ អ.វ.ត.ក ចែងថា ជនជាប់ចោទមានសិទ្ធិទទួលបានការធានាជាអប្បបរមា និងស្មើៗគ្នាសមស្របតាមមាត្រា១៤ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដែលចែងអំពីការការពារសិទ្ធិជាទូទៅរបស់ភាគី។ នៅក្នុងមាត្រា១៤(៣)(ឆ) នៃសន្ធិសញ្ញា ICCPR ផ្តល់លទ្ធភាពឲ្យជនជាប់ចោទនូវសិទ្ធិមិនផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង ឬសិទ្ធិមិនឆ្លើយសារភាពទោសកំហុស។ លើសពីនេះ វិធានផ្ទៃក្នុង ២១(១)(ឃ) នៃ អ.វ.ត.ក បានការពារ ជាពិសេសនូវសិទ្ធិរបស់ជនជាប់ចោទក្នុងការនៅស្ងៀម ហើយតុលាការត្រូវតែជូនដំណឹងដល់ជនជាប់ចោទពីសិទ្ធិជាក់លាក់ទាំងនេះ នៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី ប៉ុន្តែមិនច្បាស់ថាតើការកំណត់ពេលវេលាត្រឹមណា ដែលជនជាប់ចោទអាចនឹងប្រើប្រាស់សិទ្ធិនេះបាន ហើយថាតើកាលៈទេសៈដែលនៅជុំវិញសិទ្ធិនេះដូចម្តេចខ្លះ ដែលអាចឲ្យអង្គជំនុំជម្រះធ្វើការសន្និដ្ឋានជាអវិជ្ជមាន និងផ្អែកលើមូលដ្ឋានអ្វីដែលថា ការសន្និដ្ឋានអវិជ្ជមានអាចប៉ះពាល់ដល់ទម្ងន់នៃភស្តុតាងរបស់ **ខៀវ សំផន** និង **នួន ជា**។ មេធាវីនាំមុខ **ស៊ីម៉ូនណូហ្សត** បានផ្តល់យោបល់ថា ការប្រើសិទ្ធិនៅស្ងៀមរបស់ **នួន ជា** ស្មើនឹងការ "គំរាមកំហែង" ដោយសារតែ **នួន ជា** បានលើកឡើងថា *"ប្រសិនបើតុលាការមិនដំណើរការតាមអ្វីដែលខ្លួនចង់បានទេ ខ្លួននឹងឈប់និយាយ"*។

វាសំខាន់ណាស់ដែលត្រូវចងចាំថា សិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយសំណួរគឺជាប់ពាក់ព័ន្ធនឹងសិទ្ធិដទៃទៀត និងការធានាជាអប្បបរមា ដូចជា សិទ្ធិសន្មតទុកថាគ្មានទោស គោលការណ៍ទាំងនេះ គឺដើម្បីការពារសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ។

## ខ. សិទ្ធិរបស់ជនជាប់ចោទក្នុងការប្រឹក្សាយោបល់ជាមួយមេធាវី

សវនាការនាសប្តាហ៍នេះ ក៏បានលើកឡើងពីវិធាន ៣៥ ថ្មី នៃច្បាប់របស់ អ.វ.ត.ក ដែលផ្តល់សិទ្ធិឲ្យជនជាប់ចោទ *"ក្នុងការប្រឹក្សាយោបល់ជាមួយមេធាវីរបស់ខ្លួន"*។ បន្ទាប់ពីអង្គជំនុំជម្រះបានបញ្ឈប់ **នួន ជា** ពីការអានសេចក្តីថ្លែងការណ៍របស់ខ្លួន មេធាវី **ផេស្តមិន** បានស្នើសុំពេលប្រាំនាទីជួបប្រឹក្សាយោបល់ជាមួយ

កូនក្តីខ្លួន។ ភ្លាមៗនោះ ប្រធានអង្គជំនុំជម្រះបានបដិសេធលើសំណើនោះ បន្ទាប់មកផ្តល់ឱកាសដល់លោកស្រីចៅក្រម **ខាត់រ៉ាយច៍** ឲ្យចោទសួរសំណួរដល់ **នួន ជា** ពាក់ព័ន្ធនឹងសវនាការផ្នែកទី២។ **នួន ជា** បានបដិសេធមិនឆ្លើយសំណួរ រហូតទាល់តែគាត់អាចប្រឹក្សាយោបល់ជាមួយមេធាវីខ្លួន។ បន្ទាប់ពីការជំនុំពិភាក្សា អង្គជំនុំជម្រះបានអនុញ្ញាតឲ្យមេធាវី **ផេស្តមិន** ទៅជួបពិគ្រោះជាមួយកូនក្តីខ្លួននៅរង្វង់ក្រចកសេះ។

នៅរសៀលថ្ងៃអង្គារ ហេតុការណ៍មួយផ្សេងទៀតបានកើតឡើង ពាក់ព័ន្ធនឹងការបកស្រាយសិទ្ធិរបស់ជនជាប់ចោទ ក្នុងការប្រឹក្សាយោបល់ជាមួយមេធាវីខ្លួន។ នៅពេលដែលប្រធានអង្គជំនុំជម្រះបានអនុញ្ញាតឲ្យ **នួន ជា** ទៅតាមដានសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍នៅក្នុងបន្ទប់រង់ចាំខាងក្រោម ដោយសារតែជនជាប់ចោទមានអាការៈមិនសូវស្រួលខ្លួន។ មេធាវីបានបញ្ជាក់ថា ពួកគេបានស្នើសុំតុលាការឲ្យផ្អាកដំណើរការមុនកាលកំណត់ ដើម្បីឲ្យកូនក្តីខ្លួនសម្រាកយកកម្លាំង និងមានវត្តមាននៅពេលសាក្សី **ឌុច** មកផ្តល់សក្ខីកម្ម។ ដើម្បីបញ្ជាក់ពីស្ថានភាពសុខភាពរបស់ **នួន ជា** អង្គជំនុំជម្រះបានបង្គាប់ឲ្យក្រុមគ្រូពេទ្យប្រចាំ អ.វ.ត.ក ធ្វើការពិនិត្យរករោគវិនិច្ឆ័យឲ្យបានច្បាស់លាស់។ មេធាវី **ផេស្តមិន** ដោយពុំមានការអនុញ្ញាតពីអង្គជំនុំជម្រះ បានចូលក្នុងបន្ទប់ពិនិត្យសុខភាពកូនក្តីខ្លួន ភ្លាមៗនោះ អង្គជំនុំជម្រះ បានបង្គាប់ឲ្យមន្ត្រីតុលាការអញ្ជើញមេធាវីត្រឡប់មកវិញ និងបានណែនាំថា ប្រសិនបើមានករណីនេះនៅពេលក្រោយ *"មេធាវីនឹងមានបញ្ហា"* ដោយសារតែគាត់រំខានដល់គ្រូពេទ្យដែលពិនិត្យសុខភាព។ នៅពេល មេធាវី **ផេស្តមិន** បានត្រឡប់មកវិញ អង្គជំនុំជម្រះបានធ្វើការកត់សម្គាល់ថា មេធាវីបានជ្រៀតជ្រែកដល់ដំណើរការពិនិត្យសុខភាពរបស់ **នួន ជា** និងប្រកាសផ្អាកសវនាការនៅពេលនោះ។ ពុំមានព័ត៌មានច្បាស់លាស់ ពីមូលហេតុដែលនាំឲ្យសវនាការផ្អាក់លឿនជាងកាលកំណត់។

នៅព្រឹកថ្ងៃបន្ទាប់ មេធាវី **ផេស្តមិន** បានលើកឡើងពីបញ្ហានេះ និងធ្វើការបដិសេធលើពាក្យ *"ជ្រៀតជ្រែក"*។ មេធាវីបានអះអាងថា ក្នុងនាមជាមេធាវីការពារក្តី គាត់មានកាតព្វកិច្ចមានវត្តមាននៅក្នុងពេលពិនិត្យសុខភាពកូនក្តីខ្លួន។ គាត់បានលើកទឡ្ហីករណ៍ថា វត្តមានរបស់គាត់គឺមានសារៈសំខាន់ណាស់ ព្រោះគាត់កត់សម្គាល់ថា ការពិនិត្យសុខភាពកូនក្តីគាត់ គឺមិនបានដិតដល់ទេ ដូចជា ពុំមានការពិនិត្យលើផ្នែកសតិស្មារតី ភាពហត់នឿយអស់កម្លាំង ការផ្ចង់ស្មារតី និងសមត្ថភាពចូលរួមដំណើរការនីតិវិធី។ អង្គជំនុំជម្រះបានសម្រេចថា ក្នុងនាមជាមេធាវីការពារក្តី គឺមានសិទ្ធិតតាំងនៅក្នុងនីតិវិធីពិនិត្យសុខភាព ប៉ុន្តែមិនមានសិទ្ធិមានវត្តមាននៅក្នុងការពិនិត្យសុខភាពនោះទេ។ បន្ទាប់មក មេធាវី **ផេស្តមិន** បានស្នើសុំឲ្យមានការពិនិត្យសុខភាព **នួន ជា** ម្តងទៀត នៅពេលអាហារថ្ងៃត្រង់ និងសុំអនុញ្ញាតមានវត្តមានជាមួយកូនក្តីរបស់គាត់។ អង្គជំនុំជម្រះបានបដិសេធសំណើនេះ និងបានណែនាំគ្រូពេទ្យឲ្យធ្វើការពិនិត្យសុខភាពជនជាប់ចោទ តែពេលដែលគាត់មានស្ថានមិនភាពប្រក្រតី។ បន្ទាប់ពីសម្រាក ប្រធានអង្គជំនុំជម្រះបានគូសបញ្ជាក់ថា មេធាវីមិនអាចស្នើសុំដោយផ្ទាល់ទៅគ្រូពេទ្យដើម្បីពិនិត្យស្ថានភាពជម្ងឺកូនក្តីខ្លួនទេ សំណើនេះ គឺត្រូវធ្វើតាមរយៈក្រឡាបញ្ជី។ ចៅក្រម **ឡាវែន៍** បានបន្ថែមថា រាល់ការស្នើសុំរបស់មេធាវីចំពោះការមានវត្តមាននៅក្នុងពេលពិនិត្យសុខភាពកូនក្តីខ្លួន

នឹងត្រូវបដិសេធគ្រប់ពេល ដោយចង្អុលបង្ហាញថា ជនជាប់ចោទមិនអាចទទួលបានសិទ្ធិមានមេធាវីចូលឃ្លាំមើលការពិនិត្យស្ថានភាពសុខភាពខ្លួនឡើយ។

បញ្ហានេះ បានបង្ហាញពីភាពចាំបាច់ចំពោះការត្រួតពិនិត្យឡើងវិញលើច្បាប់ អ.វ.ត.ក និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (ឬដោយខ្វះ) បញ្ញត្តិស្តីពីវត្តមានរបស់មេធាវីនៅក្នុងពេលពិនិត្យសុខភាពជនជាប់ចោទ។ ជាងនេះទៀត បន្ទាប់ពីការសង្កេតរបស់មេធាវី **ផេស្តមិន** ដែលថា ការវាយតម្លៃវេជ្ជសាស្ត្រ គឺនៅមានកម្រិត ដូចជា ការពិនិត្យសម្ពាធឈាម គឺមានប្រសិទ្ធភាពចំពោះការផ្តល់ថ្នាំដល់ជនជាប់ចោទ ក៏ប៉ុន្តែភាពចាស់ជរារបស់គាត់ គឺមានស្ថានភាពសុខភាពផ្សេង។

## គ. ការបកស្រាយអំពី «ការពន្យារពេល» ដំណើរការនីតិវិធី

នៅថ្ងៃពុធ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី **លីម៉ា ង្វៀន** បានលើកឡើងពីបញ្ហាផ្អាកដំណើរការនីតិវិធីមុនកាលកំណត់នៅថ្ងៃអង្គារ។ មេធាវីបានលើកវិធាន ៨១(៥) និងអះអាងថា បញ្ហាសុខភាពរបស់ជនជាប់ចោទ អាចនឹងនាំឲ្យមានការពន្យារដំណើរការនីតិវិធីជាបន្តបន្ទាប់។ មេធាវីបានស្នើថា ជំនួសឲ្យការផ្អាកសវនាការមុនកាលកំណត់ សវនាការគួរធ្វើតាមរយៈប្រព័ន្ធសោតទស្សន៍ ដូច្នេះ អាចមានសមភាពរវាងសិទ្ធិរបស់ជនជាប់ចោទ និងជនរងគ្រោះ។ មេធាវី **ម៉ៃខល កាណាវ៉ាស** បានឆ្លើយតបថា ស្ថានភាពសុខភាពរបស់ជនជាប់ចោទ គឺទាំងស្ថានភាពរាងកាយ និងសតិស្មារតី មិនអាចចូលរួមសវនាការបានទេ។ មេធាវី **ផេស្តមិន** បានធានាអះអាងចំពោះអង្គជំនុំជម្រះ និងភាគីដទៃថា **នួន ជា** គឺមិនមានស្ថានភាពសុខភាពរឹងមាំទេ។ មេធាវីបានថ្លែងថា ជនជាប់ចោទមិនទាន់ធ្វើឲ្យមានការពន្យារសវនាការធំដុំ ដូចដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងទេ។ មេធាវី **ផេស្តមិន** បានលើកយកករណីសំណុំរឿង *ស្តានីស៊ីក* ដោយបានអះអាងថា ទោះបីជាមានការពន្យារដំណើរការនីតិវិធី បីខែទៅប្រាំមួយខែក៏ដោយ ក៏មិនចាត់ទុកថាជាការ «ពន្យារដំណើរការនីតិវិធី» ឡើយ។

អង្គជំនុំជម្រះមិនបានសម្រេចលើបញ្ហានេះទេ ដោយសារតែមិនមានការពន្យារដំណើរការសវនាការជាធំដុំ ដែលបង្កដោយស្ថានភាពសុខភាពរបស់ជនជាប់ចោទ។ គួរកត់សម្គាល់ថា **នួន ជា** ស្នើសុំទៅតាមដានសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍នៅថ្ងៃពុធ ក្រោយពីពេលដែលគាត់ថ្លែងថា «ហត់នឿយអស់កម្លាំង»។

## ឃ. ការប្រៀបធៀបតួនាទីរបស់សាក្សីអង្គហេតុ និង សាក្សីអ្នកជំនាញ

ក្នុងនាមជាសាក្សី **ឌុច** បានផ្តល់ព័ត៌មានជាច្រើនជុំវិញទិដ្ឋភាពនានានៃរបបកម្ពុជាប្រជាធិបតេយ្យ ដូចជា ការបកស្រាយលទ្ធិកៈបក្សកុម្មុយនីស្តកម្ពុជា និងរចនាសម្ព័ន្ធទំនាក់ទំនងរបស់បក្ស។ ប៉ុន្តែ វាលំបាកខ្លាំងណាស់ ក្នុងការបែងចែក ថាតើព័ត៌មានណាដែលគាត់ជួបប្រទះផ្ទាល់ខ្លួន និងព្រឹត្តិការណ៍ណាដែលគាត់បាន

ដឹង តាមរយៈការអាន និងមើលឯកសារនៅក្នុងសវនាការសំណុំរឿង០០១ ក៏ដូចជា សៀវភៅ ខ្សែភាពយន្ត ឯកសារ និងព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងខ្មែរក្រហមដែលគាត់បានសិក្សាស្រាវជ្រាវចាប់តាំងពីការដួលរលំនៃរបបនេះ។ មានពេលខ្លះ សក្ខីកម្មរបស់ **ឌុច** បានឲ្យដឹងថា ការផ្តល់សក្ខីកម្មរបស់គាត់ គឺផ្អែកតាមការ *"ស្រាវជ្រាវ"* ហើយ *"ប្រសិនបើចង់ឲ្យខ្ញុំនិយាយត្រឹមតែអ្វីដែលខ្ញុំដឹងនៅពេលនោះ ខ្ញុំពុំមានអ្វីប្រាប់ទេ ដោយសារតែខ្ញុំដឹងត្រឹមតែមន្ទីរស-២១"*។ ការលើកបែបនេះ បានធ្វើឲ្យមេធាវី **កាណាវ៉ាស** និងមេធាវី **ផេស្គមិន** ងើបឡើងជំទាស់ដោយហេតុផលថា ភាគីសហព្រះរាជអាជ្ញាបានប្រើប្រាស់ **ឌុច** ជាសាក្សីជំនាញ ពាក់ព័ន្ធនឹងបញ្ហាដែលគាត់បានដឹង និងធ្វើសេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងរបបកម្ពុជាប្រជាធិបតេយ្យ ជាជាងការផ្តល់សក្ខីកម្មពីបទពិសោធន៍ និងការចងចាំផ្ទាល់ខ្លួន។ ដើម្បីការពារនូវយុទ្ធសាស្ត្រនេះ ព្រះរាជអាជ្ញា **ស្មីត** បានអះអាងជាថ្មីថា **ឌុច** គឺជាសាក្សីពិសេស ដែលមិនត្រឹមតែអាចផ្តល់សក្ខីកម្មពីអ្វីដែលបានកើតឡើងនៅមន្ទីរស-២១ទេ គាត់ក៏អាចផ្តល់ព័ត៌មាន អំពីគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា និងបញ្ហាផ្សេងៗពាក់ព័ន្ធនឹងសវនាការនេះ។ គាត់បានរម្លឹកថា ភាគីការពារក្តីនឹងមានឱកាសក្នុងការចោទសួរសាក្សី អំពីប្រភព និងមូលដ្ឋានសក្ខីកម្ម ដែលសាក្សីថ្លែងប្រាប់។

អង្គជំនុំជម្រះតាមរយៈលោកស្រីចៅក្រម **ស៊ីលវៀ ខាតរ៉ាយច៍** បានយល់ស្របលើការជំទាស់នេះ ដោយថ្លែងថា ការជជែកនេះ គឺផ្តោតសំខាន់ទៅលើការយល់ដឹងរបស់ **ឌុច** ចំពោះព្រឹត្តិការណ៍ និងឯកសារនៅក្នុងសម័យនោះ។ អង្គជំនុំជម្រះនឹងពិចារណាវាយតម្លៃសក្ខីកម្មសាក្សីដែលបានសួរដេញដោលដោយភាគី។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះបានណែនាំ **ឌុច** មិនឲ្យធ្វើការវិភាគលើព្រឹត្តិការណ៍ដែលកើតឡើង និងកម្រិតការឆ្លើយសំណួររបស់ខ្លួនដោយផ្អែកតែទៅលើការយល់ដឹង និងបទពិសោធន៍ផ្ទាល់ខ្លួន។

## ង. វិសាលភាពនៃសំណួរ

នៅក្នុងខែកញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះបានចេញដីកាបំបែកនីតិវិធីដំណើរការនៅក្នុងសំណុំរឿង ០០២ ដោយធ្វើសវនាការជាផ្នែកៗ និងជជែកពិភាក្សាយ៉ាងលម្អិតនៅក្នុងផ្នែកទីមួយ។ ដំណើរការនីតិវិធីបច្ចុប្បន្ន ត្រូវបានគេហៅថាជា សំណុំរឿង០០២ ផ្នែកទីមួយ (០០២/១)។ ទោះបីជាយ៉ាងណា នៅពេលសវនាការដំណើរការ បញ្ហាលំបាកជាច្រើនពាក់ព័ន្ធនឹងការកម្រិតសំណួរទៅតាមដីកាបំបែកនីតិវិធីដំណើរការបានកើតឡើងជាហូរហែ។ ជាក់ស្តែង អង្គជំនុំជម្រះក្រើនរម្លឹកសហព្រះរាជអាជ្ញាជាច្រើនលើកឲ្យផ្តោតសំខាន់តែទៅលើសំណួរពាក់ព័ន្ធនឹងអង្គហេតុនៅក្នុងសំណុំរឿង០០២/១។ មេធាវី **ផេស្គមិន** បានធ្វើការជំទាស់ថា សំណួររបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងមន្ទីរស-២១ និងការបោសសម្អាតខ្មាំងស៊ីរូងផ្ទៃក្នុង គឺមិនស្ថិតនៅក្នុងវិសាលភាពនៃសវនាការផ្នែកទីមួយទេ។ ផ្ទុយទៅវិញ សហព្រះរាជអាជ្ញា បានអះអាងថា សំណួររបស់គាត់ គឺឆ្លុះបញ្ចាំងពីគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាដែលកំណត់នៅក្នុងដីកាបំបែកនីតិវិធីដំណើរការ និង ម្យ៉ាងថា ជួយឆ្លុះបញ្ចាំងពីសហឧក្រិដ្ឋកម្មរួម " ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ" ។ ទោះបីជាយ៉ាងណា អង្គ

ជំនុំជម្រះបានជ្រើសយកវិធីសាស្ត្របន្ធូបន្ថយ និងបដិសេធលើការជំទាស់មួយចំនួន ដោយមូលហេតុថា ជាសំណួរមិនពាក់ព័ន្ធនឹងសវនាការបច្ចុប្បន្ន និងអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាបន្តសំណួររបស់ខ្លួន។

## ច. ការបង្ហាញឯកសារចំពោះមុខសាក្សី ដើម្បីជួយរម្លឹកការចងចាំ និងបញ្ជាក់ពីយថាភាពនៃឯកសារ

សប្តាហ៍នេះ សហព្រះរាជអាជ្ញាបានចោទសួរសាក្សីអំពីឯកសារមួយចំនួន ដែលពាក់ព័ន្ធនឹងមន្ទីរ ស-២១ និងបក្សកុម្មុយនីស្តកម្ពុជា។ ទោះបីជា **ឌុច** អាចចំណាំឯកសារស្ទើរតែទាំងអស់ក៏ដោយ ក៏គាត់បានឲ្យដឹងថា គាត់មិនធ្លាប់ឃើញឯកសារចំនួនពីរច្បាប់នេះ។ នៅពេលដែលព្រះរាជអាជ្ញា **សេង ប៊ុនឃាង** ស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះដាក់បង្ហាញឯកសារទីមួយដល់សាក្សី **ឌុច** ដើម្បីរម្លឹកការចងចាំ នៅពេលនោះ មេធាវី **កាណាវ៉ាស** បានផ្តល់មតិយោបល់ថា ព្រះរាជអាជ្ញាគួរអានលេខសម្គាល់ឯកសារជាមុន មុននឹងផ្តល់ឯកសារនោះទៅឲ្យសាក្សី ដើម្បីឲ្យអង្គជំនុំជម្រះសម្រេចថាតើគួរអនុញ្ញាតឬយ៉ាងណា។ ផ្អែកតាមមេធាវី **កាណាវ៉ាស** បានឲ្យដឹងថា វាគឺជាករណីចាំបាច់ដើម្បីធានាថា សាក្សីអាចរម្លឹកការចងចាំខ្លួន ក៏ប៉ុន្តែមិនមែនទើបតែឃើញឯកសារនេះជាលើកទីមួយទេ។ សហព្រះរាជអាជ្ញា **ស្មីត** បានលើកទឡ្ហីករណ៍ថា ឯកសារដាក់បង្ហាញសាក្សីតើគាត់ស្គាល់ឯកសារនោះទេ ប្រសិនបើគាត់មិនធ្លាប់ស្គាល់ សាក្សីក៏អាចធ្វើការបញ្ជាក់ពីយថាភាពនៃឯកសារដោយចង្អុលបង្ហាញ ថាតើខ្លឹមសារនៃឯកសារនោះ មានភាពស៊ីចង្វាក់នឹងគោលនយោបាយដែលអនុវត្តជាក់ស្តែងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ មេធាវី **កាណាវ៉ាស** បានលើកទឡ្ហីករណ៍តបថា គាត់មិនបានជំទាស់ទៅនឹងការប្រើប្រាស់ឯកសារ ក្នុងការជួយរម្លឹកការចងចាំសាក្សីទេ ប្រសិនបើគាត់ភ្លេចការចងចាំ ក៏ប៉ុន្តែការបញ្ជាក់អំពីយថាភាពនៃឯកសារ គឺជារឿងផ្សេង ហើយជាការលើកឡើងដោយមិនត្រឹមត្រូវ ដោយឲ្យសាក្សីបញ្ជាក់ពីយថាភាពនៃឯកសារ នៅពេលដែលចង់រម្លឹកការចងចាំ។

អង្គជំនុំជម្រះបានអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាដាក់បង្ហាញឯកសារដល់ **ឌុច** ទោះបីជា **ឌុច** មិនធ្លាប់ឃើញឯកសារនោះពីមុនក៏ដោយ។ ព្រះរាជអាជ្ញា **សេង ប៊ុនឃាង** បានយោងព័ត៌មាននៅក្នុងឯកសារទាំងនោះ និងបានចោទសួរ **ឌុច** អំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។ មេធាវី **សុន អរុណ** ដែលជាមេធាវីការពារក្តីឲ្យ **នួន ជា** បានជំទាស់ដោយលើកហេតុផលថា ការធ្វើបែបនេះគឺមិនសមស្របទេ នៅក្នុងការចោទសួរសំណួរសាក្សីចំពោះឯកសារដែលគាត់មិនធ្លាប់ឃើញពីមុនមក។ ករណីស្រដៀងគ្នានេះ បានកើតឡើង មេធាវី **កាណាវ៉ាស** បានជំទាស់ថា សហព្រះរាជអាជ្ញាបានកំពុងនាំមុខសាក្សី។ គាត់បានតវ៉ាថា សហព្រះរាជអាជ្ញា អាចចោទសួរសាក្សីតែត្រឹមថាតើគាត់ធ្លាប់ស្គាល់ឯកសារនោះទេ។ ជាការឆ្លើយតប ព្រះរាជអាជ្ញា **ស្មីត** បានគូសបញ្ជាក់ថា ដោយសារ **ឌុច** ជាសាក្សីពិសេស ដូច្នេះ បានទទួចស្នើសុំអង្គជំនុំជម្រះឲ្យអនុញ្ញាតពួកគាត់អាចសួរសំណួរពាក់ព័ន្ធនឹងខ្លឹមសារនៃឯកសារ គឺអាចធ្វើឲ្យអង្គជំនុំជម្រះយល់កាន់តែច្បាស់ពីទំនាក់ទំនងនៃឯកសារទាំងនេះ។

បន្ទាប់ពីបានពិចារណាលើទឡ្ហីករណ៍របស់ភាគី អង្គជំនុំជម្រះបានលើកឡើងថា ប្រសិនបើសាក្សី មិនធ្លាប់ស្គាល់ឯកសារដាក់បង្ហាញ ដូចនេះ ឯកសារត្រូវដកចេញពីសាក្សី និងដកចេញពីប្រព័ន្ធកុំព្យូទ័រ។ នៅក្នុង

ករណីនេះ អង្គជំនុំជម្រះបានសម្រេចថា ភាគីមិនត្រូវសួរសំណួរដោយយោងលើឯកសារឡើយ ប៉ុន្តែពួកគេអាចសួរសំណួរពាក់ព័ន្ធនឹងព័ត៌មាននៃឯកសារនោះបាន។ ការសម្រេចនេះ បានធ្វើឲ្យសំណើរបស់សហព្រះរាជអាជ្ញាជាប់គាំង គឺសំណើសុំឲ្យសាក្សីផ្តល់មតិយោបល់លើឯកសារដែលគាត់មិនធ្លាប់ស្គាល់ បញ្ជាក់ពីយថាភាពនៃឯកសារនោះ។

## ផ្នែកទី៤៖ ការគ្រប់គ្រងសវនាការ

ការគ្រប់គ្រងសវនាការនាសប្តាហ៍នេះ គឺពិតជាមានបញ្ហាប្រឈម ដោយសារតែបញ្ហាឥរិយាបថមិនសមរម្យជាច្រើនកើតឡើងនៅក្នុងបន្ទប់សវនាការ និងការផ្លាស់ប្តូរកាលវិភាគដោយឥតព្រៀងទុក។ អង្គជំនុំជម្រះ បានធ្វើគ្រប់គ្រងសវនាការយ៉ាងមានប្រសិទ្ធភាព ទោះបីជាសវនាការនេះមានភាពស្មុគស្មាញ និងធំធេងយ៉ាងណាក៏ដោយ។

### ក. វត្តមានរបស់ជនជាប់ចោទ

សប្តាហ៍នេះ ជនជាប់ចោទទាំងបីមានវត្តមាននៅក្នុងបន្ទប់សវនាការទាំង ៣ថ្ងៃ ក៏ប៉ុន្តែមានតែជនជាប់ចោទ **ខៀវ សំផន** ដែលមានវត្តមានពេញលេញ។ ដូចសព្វមួយដង នៅចុងសវនាការវគ្គទី១ ជនជាប់ចោទ **អៀង សារី** បានស្នើសុំអង្គជំនុំជម្រះទៅតាមដានសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍ដោយសារជម្ងឺចង្កេះ និងឆ្អឹងខ្នង។

នៅថ្ងៃអង្គារ **នួន ជា** បានឲ្យដឹងថា គាត់មិនសូវស្រួលខ្លួន និងសុំទៅតាមដានសវនាការពីចម្ងាយនៅបន្ទប់សោតទស្សន៍។ ទោះបីជា **នួន ជា** បានស្នើសុំទៅតាមដានពីចម្ងាយក៏ដោយ ក៏មេធាវី **ផេសមិន** បញ្ជាក់ថា កូនក្តីខ្លួនចង់មានវត្តមាននៅក្នុងអំឡុងពេល **ឌុច** ផ្តល់សក្ខីកម្ម ដូច្នេះ ស្នើសុំឲ្យផ្អាកសវនាការបណ្តោះអាសន្ន។ នៅថ្ងៃពុធ **នួន ជា** បានស្នើសុំទៅតាមដានសវនាការពីចម្ងាយនៅបន្ទប់សោតទស្សន៍ ដោយដាក់លិខិតលះបង់សិទ្ធិរបស់ខ្លួន។

### ខ. ឥរិយាបថនៅក្នុងបន្ទប់សវនាការ

កាលពីសប្តាហ៍មុន ដោយសារតែ **នួន ជា** ហត់នឿយអស់កម្លាំងបន្ទាប់ពីផ្តល់សក្ខីកម្ម ដូច្នេះ មេធាវី **ផេស្តមិន** បានស្នើសុំថា កូនក្តីខ្លួនមិនអាចចូលរួមសវនាការនៅពេលរសៀលទេ ខណៈពេលដែលសាក្សី **ឌុច** នឹងផ្តល់សក្ខីកម្ម។ គាត់បានស្នើសុំអង្គជំនុំជម្រះឲ្យផ្លាស់ប្តូរកាលវិភាគ ដែលអាចសម្របសម្រួលឲ្យកូនក្តីខ្លួនចូលរួមបាន (ជាជាងទៅតាមដានពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍)។ អង្គជំនុំជម្រះបានយល់ព្រមតាមសំណើ និងកែតម្រូវកាលវិភាគ ដែលឲ្យជនជាប់ចោទ **នួន ជា** ផ្តល់សក្ខីកម្មនៅព្រឹកថ្ងៃច័ន្ទ និងថ្ងៃពុធ (ផ្អាកសវនាការនៅពេលរសៀល) ចំណែកឯ **ឌុច** នឹងមកផ្តល់សក្ខីកម្មនៅថ្ងៃអង្គារ និងថ្ងៃព្រហស្បតិ៍។

អង្គជំនុំជម្រះហាក់មិនសូវជាពេញចិត្ត នៅពេល **នួន ជា** បានប្រើប្រាស់សិទ្ធិនៅស្ងៀម បន្ទាប់ពីអង្គជំនុំជម្រះខំយកចិត្តទុកដាក់រៀបចំកែសម្រួលកាលវិភាគសម្រាប់ឲ្យជនជាប់ចោទចូលរួម។ ចៅក្រម **ហ្សង់ម៉ាក់ ឡាវែន៍** ក្នុងនាមអង្គជំនុំជម្រះ បានថ្លែងថា មេធាវីការពារក្តី **ផេស្តមិន** មិនបានបង្ហាញឲ្យច្បាស់លាស់ធ្វើឲ្យតុលាការមានការយល់ខុស។ ជាងនេះទៀត ចៅក្រមបានចង្អុលបង្ហាញថា លក្ខខណ្ឌរបស់ **នួន ជា** ដែលលើក

ឡើងថា គាត់នឹងផ្តល់សក្ខីកម្ម ប្រសិនបើពិភាក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ហើយបានប្រើប្រាស់សិទ្ធិនៅស្ងៀម ប្រសិនបើអង្គជំនុំជម្រះសម្រេចចាប់ផ្តើមសវនាការផ្នែកទី២ គឺជាចេតនាបោកបញ្ឆោតអង្គជំនុំជម្រះ។ អង្គជំនុំជម្រះយល់ឃើញថា ករណីនេះ គឺជា “ កំហុសវិជ្ជាជីវៈយ៉ាងធ្ងន់ធ្ងរ” និងថ្លែងថា បញ្ហានេះនឹងយកមកពិចារណានាពេលអនាគត។ មេធាវី **ផេស្តមិន** មិនបានតក់ស្លុតនឹងការស្តីបន្ទោសនោះទេ ដោយបានថ្លែងពីភាពជឿជាក់ចំពោះទង្វើរបស់ខ្លួន។ គាត់បានជម្រាបអង្គជំនុំជម្រះថា គាត់ស្វាគមន៍ចំពោះចំណាត់ការសព្វគ្រប់បែបយ៉ាង ដែលអង្គជំនុំជម្រះនឹងធ្វើ ហើយថែមទាំងស្ម័គ្រចិត្តផ្តល់ព័ត៌មានទំនាក់ទំនងលម្អិតរបស់គណៈមេធាវីកម្ពុជា និងគណៈមេធាវីហូឡង់ និងបញ្ជាក់ថា គាត់ចង់បានមតិយោបល់ពីអ្នកជំនាញចំពោះបញ្ហានេះ។ ជុំវិញបញ្ហាដែលមេធាវីទៅតាមដានការពិនិត្យសុខភាពកូនក្តីខ្លួន ដោយមិនមានការអនុញ្ញាតពីអង្គជំនុំជម្រះ ក៏ជាឥរិយាបថមិនសមរម្យ។ អង្គជំនុំជម្រះបានចាត់ទុកថា ទង្វើនេះ គឺជាការជ្រៀតជ្រែកកិច្ចដំណើរការវិនិច្ឆ័យសុខភាពរបស់ **នួន ជា**។ ទោះបីជាយ៉ាងណា មេធាវី **ផេស្តមិន** មិនទទួលស្គាល់ថា ទង្វើទាំងនេះ គឺមិនមែនជាកំហុសវិជ្ជាជីវៈទេ។

ម៉្យាងវិញទៀត មេធាវី **ផេស្តមិន** បានលើកពីការការពារសិទ្ធិរបស់កូនក្តីរបស់ខ្លួន ដែលការតាំងចិត្តនេះ មិនបញ្ឈប់មេធាវីឲ្យធ្វើការតតាំងជាមួយអង្គជំនុំជម្រះ និងភាគីនានាទេ។

ជនជាប់ចោទក៏បានតតាំងដោយខ្លួនឯងពីបញ្ហាមិនសមរម្យមួយចំនួននៅក្នុងបន្ទប់សវនាការ។ នៅថ្ងៃអង្គារមុនសម្រាកអាហារថ្ងៃត្រង់ **នួន ជា** បានកាត់សំណួររបស់ព្រះរាជអាជ្ញា **សេង ប៊ុនឃាង** ដោយថ្លែងថា *“គេមិនដែលយកឈើពុក ឈើស្អុយរលួយទៅឆ្លាក់ធ្វើព្រះ ហើយយកព្រះនោះមកទេសនាឲ្យប្រជាជនស្តាប់នោះទេ”*។ ការលើកឡើងនេះ គឺជាការធៀប **ឌុច** ទៅនឹងឈើពុក ដែលថា **ឌុច** មិនមែនជាមនុស្សដែលគួរឲ្យទុកចិត្តទេ។ កាយវិការមិនសមរម្យនេះ បានធ្វើឲ្យមេធាវីនាំមុខ **ពេជ អង្គ** ស្តីបន្ទោស និងថ្លែងរម្លឹកថា **ឌុច** *“ត្រូវបានទទួលស្គាល់ថាជាសាក្សី វាមិនគួរលើកឡើងដែលអាចវាយប្រហារចំពោះសាក្សីទេ ទោះតាមរូបភាពណាក៏ដោយ”*។ អង្គជំនុំជម្រះបានដាស់តឿនទៅ **នួន ជា** ឲ្យរក្សាភាពអត់ធ្មត់ និងស្តាប់សក្ខីកម្មរបស់សាក្សី។

## គ. ការគ្រប់គ្រងពេលវេលា

ការអនុវត្តសិទ្ធិនៅស្ងៀមរបស់ **នួន ជា** បានធ្វើឲ្យមានការកែប្រែកាលវិភាគ ដែលនេះបង្ហាញពីភាពបត់បែនរបស់អង្គជំនុំជម្រះ។ អង្គជំនុំជម្រះបានសម្រេចភ្លាមៗកោះអញ្ជើញសាក្សី **ឌុច** ចូលខ្លួនមកផ្តល់សក្ខីកម្មនៅរសៀលថ្ងៃច័ន្ទ (ជំនួសឲ្យថ្ងៃអង្គារ តាមកាលវិភាគតុលាការ) និងកំណត់កិច្ចប្រជុំពិភាក្សាពីបញ្ហានានានៅថ្ងៃព្រហស្បតិ៍ (ជំនួសឲ្យរសៀលថ្ងៃច័ន្ទ និងរសៀលថ្ងៃពុធ បន្ទាប់ពី **នួន ជា** ផ្តល់សក្ខីកម្ម)។

## ឃ. ការចូលរួមពីសាធារណជន

សវនាការនៅសប្តាហ៍នេះ មានសាធារណជនចូលរួមយ៉ាងច្រើនកុះករ ដោយសារតែកិច្ចប្រឹងប្រែងរបស់ការិយាល័យកិច្ចការសាធារណៈ។ នៅថ្ងៃច័ន្ទ មានអ្នកចូលរួមប្រមាណ ៤០០នាក់ មកពីខេត្តកំពង់ឆ្នាំង និងដើមបណ្តឹងរដ្ឋប្បវេណីប្រមាណជា ២០នាក់ តាមដានដំណើរការសវនាការ។ ចំនួនអ្នកចូលរួមធ្លាក់ចុះនៅពេលរសៀល ដោយសារតែពុំមានផែនការសវនាការនៅពេលថ្ងៃ យោងតាមកាលវិភាគ។

នៅថ្ងៃអង្គារ អ្នកចូលរួមតាមដានសវនាការប្រមាណជា ៤០០នាក់ មកពីខេត្តកំពង់ស្ពឺ រួមមាន ព្រះសង្ឃ ដូនជី អ្នកភូមិ និងសិស្សានុសិស្ស ព្រមទាំង ភ្ញៀវជាតិ និងអន្តរជាតិ ប្រមាណជា ១០០នាក់ មកពី បណ្តាអង្គការនានា និងស្ថាប័នសារព័ត៌មាន មានវត្តមាននៅក្នុងសាលសាធារណជន។ នៅពេលរសៀល សិស្សានុសិស្សជាង ១០០នាក់ មកពីវិទ្យាល័យជម្លូវ័ន្ត បានមកជំនួសសិស្សានុសិស្សវិទ្យាល័យកំពង់ស្ពឺ។

នៅថ្ងៃពុធ វត្តមាននិស្សិតប្រមាណជា ៣០០នាក់ មកពីសាកលវិទ្យាល័យចំនួនពីរ ប្រជាជនជាង ១០០នាក់ មកពីខេត្តកណ្តាល និងដើមបណ្តឹងរដ្ឋប្បវេណី ៣០នាក់ បានចូលរួមសវនាការ។ មន្ត្រីបុគ្គលិក តុលាការ បានគ្រប់គ្រងស្ថានភាពបានយ៉ាងល្អ ទោះបីជាមានអ្នកចូលរួមយ៉ាងច្រើនលើសលុប ជាពិសេស នៅថ្ងៃអង្គារ។

### ង ) តារាងពេលវេលា

| កាលបរិច្ឆេទ | ចាប់ផ្តើម | សម្រាក ពេលព្រឹក | អាហារថ្ងៃត្រង់ | សម្រាក ពេលរសៀល | បិទសវនាការ | ចំនួនម៉ោងសរុប |
|---|---|---|---|---|---|---|
| ថ្ងៃច័ន្ទ ១៩/០៣/១២ | ៩:០១ | ១០:០៨ - ១១:០១ | ១១:១៣ -១៤:០៦ | ១៤:៥៨ - ១៥:២១ | ១៦:១៦ | ៣ម៉ោង និង ៦នាទី |
| ថ្ងៃអង្គារ ២០/០៣/១២ | ៩:០៥ | ១០:៣១ - ១០:៥០ | ១២:០១-១៣:៣៣ | ១៤:៤០ - ១៥:០០ | ១៥:២០ | ៤ម៉ោង និង ៤នាទី |
| ថ្ងៃពុធ ២១-/០៣-/១២ | ៩:០៨ | ១០:៤១ - ១១:០៨ | ១២:០៣-១៣:៣៣ | ១៤:៤០ - ១៤:៥៨ | ១៦:០២ | ៤ម៉ោង និង ៣៩នាទី |

**ចំនួនម៉ោងជាមធ្យមក្នុងមួយថ្ងៃ :** ៣ ម៉ោង និង៥៦នាទី
**ចំនួនម៉ោងសរុបក្នុងសប្តាហ៍ :** ១១ ម៉ោង និង ៤៩ នាទី
**ចំនួនម៉ោង ថ្ងៃ សប្តាហ៍សរុបនៅពេលជំនុំជម្រះក្តី :** ១៦៨ ម៉ោង និង ០៩នាទី

*រយៈពេលសវនាការចំនួន ៣៩ថ្ងៃ អំឡុងពេល ១១សប្តាហ៍*

**Unless specified otherwise,**

- the documents cited in this report pertain to The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan (Case No. 002/19-09-2007-ECCC) before the Extraordinary Chambers in the Courts of Cambodia;
- the quotes are based on the personal notes of the trial monitors during the proceedings;
- photos are courtesy of the ECCC.

**Glossary of Terms**

| | |
|---|---|
| Case 001 | *The Case of Kaing Guek Eav alias "Duch"*(Case No. 001/18-07-2007-ECCC) |
| Case 002 | *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* (Case No. 002/19-09-2007-ECCC) |
| CPC | Code of Criminal Procedure of the Kingdom of Cambodia (2007) |
| CPK | Communist Party of Kampuchea |
| CPLCL | Civil Party Lead Co-Lawyer |
| DK | Democratic Kampuchea |
| ECCC | Extraordinary Chambers in the Courts of Cambodia (also referred to as the Khmer Rouge Tribunal or "KRT") |
| ECCC Law | Law on the Establishment of the ECCC, as amended (2004) |
| ERN | Evidence Reference Number (the page number of each piece of documentary evidence in the Case File) |
| FUNK | National United Front of Kampuchea |
| GRUNK | Royal Government of National Union of Kampuchea |
| ICC | International Criminal Court |
| ICCPR | International Covenant on Civil and Political Rights |
| ICTR | International Criminal Tribunal for Rwanda |
| ICTY | International Criminal Tribunal for the former Yugoslavia |
| IR | Internal Rules of the ECCC Rev. 8 (2011) |
| KR | Khmer Rouge |
| OCIJ | Office of the Co-Investigating Judges |
| OCP | Office of the Co-Prosecutors of the ECCC |
| RAK | Revolutionary Army of Kampuchea |
| VSS | Victims Support Section |
| WESU | Witness and Expert Support Unit |

EAST-WEST CENTER

AIJI TRIAL MONITORING

WAR CRIMES STUDIES CENTER
UNIVERSITY OF CALIFORNIA, BERKELEY

---

* This issue of KRT Trial Monitor was authored by Mary Kristerie A. Baleva, Nora Fuchs, Princess Principe, Vidjia Phun and Noyel Ry, Penelope Van Tuyl as part of AIJI's KRT Trial Monitoring and Community Outreach Program. KRT Trial Monitor reports on Case 002 are available at <www.krtmonitor.org>, <http://forum.eastwestcenter.org/Khmer-Rouge-Trials/> and <http://socrates.berkeley.edu/~warcrime/>. AIJI is a collaborative project between the East-West Center, in Honolulu, and the University of California, Berkeley War Crimes Studies Center. Since 2003, the two Centers have been collaborating on projects relating to the establishment of justice initiatives and capacity-building programs in the human rights sector in South-East Asia. The Program is funded by the Open Society Foundation, the Foreign Commonwealth Office of the British Embassy in Phnom Penh, and the Embassy of Switzerland in Bangkok.

[1] According to Duch, the “strategic lines” suggested that mankind has to transform from slavery and feudalism of a capitalist regime to a socialist regime and finally to a communist regime. It is linked to the principle of dialectical materialism. These texts help people to transform from one regime to the next and to adapt to the change. According to the document, the party is supposed to struggle until the completion of the mission.

[2] The aim of the “tactical lines” was to gather forces to win over the enemies. There were three tactics: one to convince them to be their forces, the second to neutralize the forces which were not sure which side they should take on, and third was to isolate the enemies and have them smashed. Duch, however, questioned the applicability of these theories.

[3] Nuon Chea also explained the principle of “democratic centralism” during the Opening Statements on 13-15 December 2011. See KRT Trial Monitor Issue No. 7. 3.

[4] Co-Prosecutors. “Co-Prosecutor’s Request for Notice to be Given to Khieu Samphan on the Consequences of a Refusal to Respond to Questions at Trial” (17 February 2012). E174. 9-10. Para. 21-23; 26, citing Prosecutor v. Katanga and Chui. ICC-01/04-01/07. “Decision on the Request of the Defence for Mathieu Ngudjolo to obtain assurances with respect to self-incrimination of the accused” (13 September 2011). Para. 7,8; Prosecutor v. Gotovina et al. “Decision on theJoint Defence Motion to Prohibit Use of Defense Documents by the Prosecution” (5 December 2008). Para. 9.

[5] See Khieu Samphan Defense. Response to the “Co-Prosecutors’ Request for Notice to be Given to Khieu Samphan on the Consequences of a Refusal to Respond to Questions at Trial”. Re E174/1/Corr-2. 2 March 2012. pars. 12-21.

[6] See KRT Trial Monitor Issue No. 5 (21-23 November 2011), 6-8. See also Issue No. 7 (13-15 December 2011), 7-9.